"Sovannahong"
R. 6 24-9-53.

# សុវណ្ណហង្ស

## វគ្គ ៤



B-2
D-292
N-2923

ទូទី
119

# បញ្ជីសៀវភៅរបស់បណ្ណាគារ

## ជីង-ហ្វួង-ហ្វួត

លេខ ៣០ សួនវិថី ប៉ាស្ទ័រ ក្រុងភ្នំពេញ គឺ:

| | | | |
|---|---|---|---|
| ១- | ពុទ្ធប្រវត្តិពាក្យកាព្យ | ថ្លៃ | ១៧៛០០ |
| ២- | កេសដ្ឋក្ខន្ទក ទី ៦ | ថ្លៃ | ២០៛០០ |
| ៣- | ប្រស្នាពុទ្ធសាសនា | ថ្លៃ | ៨៛០០ |
| ៤- | សុន្ទរកថា | ថ្លៃ | ៧៛០០ |
| ៥- | យកាក់សធម៌ និង ច្បាប់ទូន្មានកូនចៅ | ថ្លៃ | ៥៛០០ |
| ៦- | សំវេគកថា | ថ្លៃ | ៤៛៥០ |
| ៧- | ប្រជុំពុទ្ធភាសិត | ថ្លៃ | ៨៛០០ |
| ៨- | បញ្ហាសង្គម | ថ្លៃ | ១៤៛០០ |
| ៩- | បុគ្គលកថា | ថ្លៃ | ៥៛០០ |
| ១០- | ហិបហោះ | ថ្លៃ | ៨៛០០ |
| ១១- | សន្និសីទ ស្តីពីសាសនា, បទបញ្ញត្តិ គោលធម៌របស់-សាសនា និងការឧបត្ថម្ភព្រះពុទ្ធសាសនា | ថ្លៃ | ៥៛០០ |
| ១២- | ប្រស្នាវិនយបញ្ញត្តិ ទី ១ | ថ្លៃ | ៧៛០០ |
| ១៣- | ,, ទី ២ | ថ្លៃ | ១២៛០០ |
| ១៤- | ប្រជុំសិក្ខាបទ | ថ្លៃ | ១០៛០០ |
| ១៥- | សន្ទនាត្រៃភាសាខ្មែរ-បារាំង-យួន | ថ្លៃ | ១៥៛០០ |
| ១៦- | សរសេរតាមសូត្រ-ពន្យល់ | ថ្លៃ | ២០៛០០ |
| ១៧- | រឿងម៉ាកប៉ាយុរកែវ ទី ១-២-៣ | ថ្លៃ | ៩៛០០ |

P.K-18
1953-4
ប.2
ARCHIVES NATIONALES RÉGIE DU DÉPÔT LÉGAL
ARCHIVES NATIONALES COTE B-114-1366
82



# បទព្រហ្មគីតិ

កាលអគ្គព្រះក្សត្រា មានមេត្តាស្នេហាច្បាស់ ទើបទ្រង់មានរាជ
ភាសន៍ ព្រះអគ្គត្រាស់ហៅសុរិយគ្គ ៗ ជាហៃកូនមាសស្ងួន មក
បជូនទឹងចមពង្ស ដ្បិតព្រះសុវណ្ណហង្ស ស្តេចមានទ្រង់មកដល់
ហើយ ៗ កាលនាងរតនពិសី ឮរបីហៅត្រាណាត្រើយ នាងមិន
បង្អង់ឡើយ ចេញមកហើយគាល់ភស្តា ៗ ឃើញនាងអកឹមស្រី
ស្រស់ប្រឹមប្រិយនាងមិនថា សុវណ្ណហង្សអគ្គក្សត្រា មានទុក្ខថានាង
ន ៗ ជាហៃអកឹមបង ពេលនេះម្តងបូរមាសស្ងួន បង្គំស្រស់មាស
ប្អូន ត្រូវទុនខ្លួនកុំរញ្ញា ៗ បង្គំកេតសុរិយគ្គ នាងមានទ្រង់ត្រូវផាយា
មហេសីដើមពំនាំ បូរឡាណាមាសបង ៗ អកឹមនាងលើកហត្ថ
សករថ្វាត់ឥតមានធ្ងង់ បង្គំស្រស់ខ្លួនល្អង ហើយសូមសុំនៃទោសា ៗ
តាំងខ្លួនជាប្អូនពិត ថ្វាយជីវិតដល់កញ្ញា តាមតែទ្រង់មេត្តា ពីពីកា
ស្រស់កល្យាណា ៗ ដោមឆាយកេតសុរិយគ្គ ឃើញអនង្គនាង
ទុនប្រាណ ក៏ទន់ព្រះទ័យក្សាន្ត ស្នេហ៍កល្យាណាជាប្អូនពិត ៗ សុខ
សប្បាយកាយបុរី ពស្ត្រីប្រុសស្រីនៅស្មេស្និត គោរពម្ចាស់ជីវិត ខ្វាប
ទ្រង់បុទ្ធិផ្ទើមបុរី ៗ អកឹមកេតសុរិយគ្គ តាំងពីពេលរង្វាប់នរបតី មិន
ដែលទាស់ពីអ្វី តាំងរបិតាមាតា ៗ សប្បាយមិនមានទុក្ខ សឹងបាន
សុខគ្រប់រូបា សប្បាយកាយសេមា ស្មេះបរបាត្រង់នេះហើយ ៗ
ទឹកថៃងពីឯយក្ស មានបុទ្ធិស័ក្តិអគ្គត្រាណាត្រើយ បេះល្បីពុំកន្តើយ

សឹងបានស្បៀមបុរីផ្ទ ។ ព្រះនាមទ្រង់ក្រៃមាត្យ ព្រះច័យស្អាតមាន
កំណត់ មហេសីទីវត្ត នៅតែបុត្រីកើតឆាយ ។ ព្រះនាងកែ
ល្អណាស់ ដូចថ្ងៃរះភ្លឺស្រុះសាយ គ្រប់អស់រូបកាយ កើតពណ្ណរាយ
លើសអស់គេ ។ កាត់សក់ទុករ៉ៃ ៗ ឥតសង្ស័យស្រស់មាសមេ សាច់
នាងពីបុព្វ ផ្ទុំក្លិនស្រស់ដូចផាផ្កា ។ ម្រាមដៃសឹងតូច ៗ មើល
ទៅស្រួចដូចបន្ទា ដងខ្លួនដូចអប្សរា គួរស្នេហាតាំងប្រុសស្រី ។ ព្រះ
នាមកមល្វកា ជាកញ្ញាបុត្រអាសុរី ព្រះនាងគ្មានស្វាមី ដោយរកប្ដី
ផ្ទឹមមិនបាន ។ ថ្ងៃមួយកំពលយក្ស កើតអួលអាក់ទឹកលេវ្រណា ទើប
យក្សមកគិតគាន តាំងរះឈ្ងននៅក្នុងចិត្ត ។ ថារូបកូនអញនៃ ពេញ
ល្អក្រៃដូចវិចិត្រ បេ្តះយកសារព្រេងព្រឹទ្ធ គ្រឹមកពិតពីបិតា ។ រូប
ហើយអញទងស្ដី ឲ្យអាសុរនៃយក្ស ដូចជុំលើកសរថ្វា រួចកាលណា
ឲ្យបុត្រស្ងួន ។ គិតស្រេចអាសុរមារ បរម្មាយ៉ាងយាំមួន យកសរ
របស់ខ្លួន មកដាក់នៅមុខរោងជ័យ ។ ហើយប្រាប់អស់អាមាត្យ ឲ្យ
សង្កាត់ប្រុងទីទៃ ប្រាប់អស់ពួកយក្សព្រៃ ទីងយក្សស្រុកផងទាំង
ឡាយ ៗ ថាបើបុគ្គលណា លើកសរថ្វាក្សត្រដោមឆាយ ឲ្យរួចលោក
មិនស្ដាយ ឲ្យបុត្រីស្រីមានទ្រង់ ។ អាមាត្យស្ដាប់ខុត្ករ លើក
ហត្ថាថ្វាយបង្គំ ហើយចេញទៅក្រៅក្រុង ប្រុងប្រាប់អស់យក្សនានា ។

## បទកាកគតិ

អស់ពួកសេនី ខំប្រឹងឃ្មាតខ្មី ប្រាប់យក្សគ្រប់គ្នា ដូចក្រុងអាសុរ៍

ពេញទាំងភាគ មកពីរង៉ើរផាស ៗ យក្ស
ក្សមានពូជពង្ស ខ្ទះក៏យកបាស់ ប្រើនក្រៃអនេក មក
ណាស់ តាមព្រះរាជសាសន៍ ក្រុងអាសុរី ៗ ថាបើអ្នកណា
លើករូបសរថ្មា នឹងឲ្យបុត្រី ព្រមទាំងសេមា ផ្ញើស្ដេចផែនដី ហេតុ
នោះឯងនៃ បានរំកន្ទង ៗ សូម្បីទេវតា ប្រឹងប្រែងម្មា រំលើក
ឥតហ្វង មិនទាំងកក្រើក ដល់សរថាម្ដង ព្រមទាំងយក្សផង គ្មាន
រួចតិចឡើយ ៗ ចាស់ក្មេងសុទ្ធយក្ស ជាងបម៉ឺននាក់ រំប្រឹងឥត
ស្បើយ លើកមិនរួចសោះ ដូចខ្មោចជាត្រើយ សែនប្រឹងណាស់
ហើយ មិនរួចដោយពិត ៗ ព្រមទាំងទេវតា រំប្រឹងអស្ចារ្យ បង់
បានរៃមិត្រ ទឹកសំបៀកគម រំអស់ពិចិត្ត ស្មើរស្មូនជីវិត ពុំរួច
ឡើយនៃ៎ ៗ ព្រួយស្មុះសាយ ដល់ក្សត្រនោមឆាយ សុវណ្ណហង្ស
នរបតី ថានគរយក្ស ឲ្យលើកសរថ្ម រួចហើយមានជ័យ ឲ្យកូន
ធេតឆាយ ៗ ស្ដេចបានដឹងជាក់ កើតក្ដីស្មោះស្ម័គ្រ ដោយបុទ្ធី
សាយ ចង់លើកឲ្យល្បី ឲ្យយក្សដឹងកាយ ទើបលោមពណ្ណកាយ
ទាំងពីរកញ្ញា ៗ ហៃកេតសុរិយង្គ នឹងកែវភេទង្គ អកិមជីវ៉ា បង
សូមលាស្រី ទៅផែនយក្សា នឹងលើកសរថ្មា យកកូនស្រីយក្ស ៗ
ហេតុនេះសូមស្រី នៅនឹងវរបី កុំឲ្យរួលអាក់ បង់ទៅមិនយូរ វិលវិង
ដោយស្ម័គ្រ នឹងមករួមរក្ស ប្អូនស្រីទាំងពីរ ៗ ទៅតែបីឆ្នាំ បូរនាង
ព្រាំចាំ សនព្វកូមី មិនឲ្យឃ្លាតទេ ហៃកែវជីវី នឹងមកការទី ប្អូន

ស្រីកល្យាណ ៗ នាងនាថបានស្តាប់ ព្រះបង្គំសា [illegible]

ក្នុងប្រាណ ទើបលើកអញ្ជលី ទាំងពីរស្មោះស្មាន [illegible]

ជាអង្គស្វាមី ៗ បពិត្រព្រះបង្គំ ឆាប់វិលជាមួង [illegible]

គង់នៅយូរ ពោលកល្យាណី ភាណិតសំដី សន្យាប្រាកដ ៗ ស្តេច

ស្តាប់មហេសី មានចិត្តមេត្រី ភាណិតវរ័ត្ន ទ្រង់យាងចុះផ្គង ឡើង

ប្រាសាទរត្ន ដល់ហើយលើកហត្ថ បង្គំបិតា ៗ បពិត្រព្រះគុណ ព្រះ

អង្គមានបុណ្យ ក្នុងពេលនេះណា បង្គំសូមលា ទៅដែនយក្សា នង

លើកសរថ្វា យកភពបុត្រ ៗ ដ្បិតអង្គក្រៃមាត្យ មានបុត្រយ៉ាងស្អាត

ញាំងពួកអាសុរ ឲ្យលើកសរថ្វា រួចឲ្យធ្វើបី រកអ្នកបេះល្បី ណាព្រះ

គុណអើយ ៗ ព្រះបាទសុធន់ រត្នស្តាប់កូនគន់ ទើបអង្គត្រាណត្រើយ

ថាអើបុត្រក្លា បិតាចាស់ហើយ កុំទៅយូរឡើយ ឆាប់វិលណា

ស្ងួន ៗ ស្តេចស្តាប់បិតា រួចហើយក្សត្រា បង្គំបក្រពាន្ត ចរចុះមកដី

យកជ័យមែនមាន យាងត្រាប់រកពន ក្នុងដងព្រឹក្សព្រៃ ៗ មិនខ្វាច

នឿយហត់ យាងចេញពីរដ្ឋ ក្នុងពេលនោះខៃ យាងមិនមានឈប់

ដោយម្លប់ឈើព្រៃ ឥតគក់ស្លុតភ័យ ព្រះទ័យជាម្ដង ៗ លុះព្រះសុរិយេ

សុរិយន់ទាបទេ ជិតយប់ហើយហោង ព្រះអង្គនឿយព្រួយ ចូលសម្រាក

ខ្លួន ឲ្យបាត់មួហ្មង ព្រឹកយាងតទៅ ៗ ចូលក្រោមម្លប់ជ្រៃ

ព្រះអង្គគ្មានភ័យ ដល់កាយព្រះទៅ ស្រួលកាយព្រះអង្គ បញ្ចាំងទិត្យ

នៅ លុះភ្លឺស្រឡៅ រឿងរះភ្លឺច្បាស់ ៗ ទើបអង្គពោធិ ព្រះអង្គចរលី

ឲ្យបានរហ័ស គ្មានគិតនឿយព្រួយ ព្រះកាយនៃម្ចាស់ ទ្រង់ទំយាន
ណាស់ ៧ទៅ ៗ ដល់នគរយក្ស ក៏ទ្រង់យល់ជាក់ ដោយឃើញ
ពួកមារ មកមីរប្រើនក្រៃ នៅកណ្តាល លើកសរគុមា ក្រៃមាត្យ
ឧត្តម ៗ ព្រះអង្គយាងចូល តាមមនុស្សមីរមួល ទើបអង្គបរម យាង
ទៅប្រញាប់ ដោយស្តេចទ្រង់ទំ ពួកយក្សមើលជុំ សើចចំអកថា ៗ
អើ! នៃពួកយើង មើលមនុស្សទើងមើង ដើរមកពីណា ខ្លួនតូចប៉ុនវៃ
ធ្មើបុកសង្ហា មកលើកសរប្ញា ភ្លើ ៗ ឥតគិត ៗ ខ្លួនគេប៉ុនកុំ្ណ មានរូប
ជំ ៗ លើកសរព្រើនយឺត ខ្លួនប៉ុនកូនចាប មកមិនពិនិត្យ អាមនុស្ស
កំទេច មុខដូចស្វាព្រៃ ៗ ស្តេចស្តាប់ពាក្យយក្ស ធ្វើមិនព្រួជាក់
ទុកកង់ព្រះទ័យ ទំយាងបានដល់ ទៅចាប់សរវៃ ទើបក្សត្រគិតលៃ
ចាប់លើកតែម្តង ៗ លើករួចដូចចិត្ត ព្រះអង្គទ្រង់យឹត បាញ់សរ
ព្រួកង់ ហាក់ដូចរន្ទះ ខ្លាំងណាស់កន្ទង់ យក្សឃើញច្បាស់ច្បង ខ្លាច
អង្គក្សត្រក្សត្រ ៗ កក្រើកលាន់ក្រៃ ព្រួទៅដល់ព្រ ព្រហ្មលោក
សួគ៌ឋាន ទ្រង់ឲ្យពរជ័យ ថ្វាយដល់ក្សត្រក្សត្រ យក្សខ្លាចអង្គប្រាណ
ព្រះមុនិន្ទ្រពេកពន់ ៗ យក្សខ្លាចអស្ចារ្យ បុទ្ធិព្រះករុណា ជាអនេក
លន់ ព្រួកង់សព្វសាយ ទេវតារយពាន់ ថ្វាយពរច្រើនលាន់ ដល់
ព្រះចក្រ ៗ រន្ទឺសុះសាយ ស្រុកយក្សជិតឆ្ងាយ ខ្លាចព្រះនរបតី
ថ្វើនអង្គក្រៃមាត្យ យក្សមានសេរី ហៅអង្គក្សត្រថ្វៃ សុវណ្ណហង្សក្សត្រ
ក្សត្រ ៗ ជាហៃហបុត្រីស្នួន គូព្រេងផ្សងផ្គួន នៃនគរកលព្រាណ ទីង

នាងកមល្ទុកា ជាស្រីចំណាន គឺបុណ្យព្រេងបាន មកជួបកូនស្ងួន ៗ ប្ដេះប្ដូរបុរាទៅ ដំណាក់មួយនៅ ឲ្យបានស្រួលខ្លួន រួចស្រេចអភិសេក នឹងកូនទឹមនួន សោយរាជ្យមាំមួន ក្នុងពេលនេះហើយ ៗ ព្រះអង្គបាន ស្ដាប់ បង្គំតាមច្បាប់ យាងពុំយូរឡើយ ទៅរាជដំណាក់ ឲ្យស្រាក ទុក្ខស្បើយ ទ្រង់គង់កន្ដើយ បានស្រួលព្រះអង្គ ៗ ឯអង្គក្រៃមាត្យ ព្រះទ័យស្ដេចស្អាត ទើបត្រាស់ទៅគ្រង់ នាងកមល្ទុកា ព្រះទ័យបញ្ចង្គ អើកែវវរវង្ស មាសស្ងួនបិតា ៗ ឥឡូវគូស្រី លើកសរួចខ្ចី ជាតិ ជាមនុស្ស ប្ដេះប្ដូររៀបកាយ យើងនឹងគិតការ រៀបកូនធីតា ធ្វើ ជាមហេសី ៗ នាងនាថបានស្ដាប់ ត្រេកអរចំណាប់ កបកល្យាណី នាងត្រេកអរណាស់ ពុថាបានប្ដី មិនដែលស្គាល់អី ខាងចំណីល្អ ៗ រៀបកាយយប់នោះ ពាល់តែក្លិប្រាស់ រស្មីចេញបរ នាងចង់បានប្ដី លាបម្សៅយ៉ាងល្អ ពាល់តែឡើងស ដូចស្រីសួគ៌ា ៗ លុះព្រឹកស្រេច ហើយ ក្រុងយកក្សត្រាណាត្រើយ ហៅអស់ពលមារ ថារុយគ្នាយើង រៀបប្រាណម្ចីម្ចា នឹងផ្សំផ្គុំគ្នា បុត្រាបុត្រី ៗ ពលយកស្របព្យាយ ដឹងបានអង្គកាយ បានអង្គម្ចាស់ថ្មី រៀបគ្រឿងប្រដាប់ ឆាប់តាំងប្រុស ស្រី ឲ្យម្ចាស់មានល្បី ដូចក្ដីប៉ុនប៉ង ៗ រួចហើយកាលណា ឡើង ទូលយកក្រ ក្រៃមាត្យជាប្យង ជាសូមព្រះអង្គ ក្សត្រជាបជាម្ដង គ្រឿង សព្វគ្រប់ផង ធ្វើរួចអស់ហើយ ៗ ព្រះអង្គបានស្ដាប់ សេនីសាសព្វ គ្មានសល់សោះឡើយ ហៅរាជបុត្រី នឹងអង្គត្រាណាត្រើយ ធ្វើកិច្ច

បង្ហើយ ក្នុងពេលនោះនៃ ៗ យាងព្រះសុវណ្ណហង្ស ទឹងដោម អនង្គ កមលុតាប្រពៃ ទ្រង់រៀបអភិសេក ជាឯកក្រុងក្រៃ ក្នុងពេល នោះនៃ សប្បាយអស្ចារ្យ ៗ ស្តេចទឹងនាងស្រី គង់យ៉ាងគប្បី ល្អ ដូចទេវតា មើលទៅប្លែកក្នេក គង់ទឹមគ្នាណា ពួកពលយកក្បា សរសើរ អឹងកង ៗ ពលយកក្រថ្វាយពរ ដល់ព្រះភូធរ ប្រិនក្រៃកន្ទង ជា សូមព្រះអង្គ ទឹងកែវទូទល្អង ភ្លើស្តេចចម្បង គ្រងកពជបុរី ៗ សូម ឲ្យបានសុខ ព្រមយកប្រាំងស្រុក ទីពឹងក្សត្រី ទឹងអង្គក្សត្រា ម្ចាស់ មានសេរី សុខដោយបារមី ព្រះគុណនេះឯង ៗ លុះរួចកិច្ចកល តាម ដោយយោបល់ នៃព្រះគម្តែង លុះដល់ព្រលប់ យាងចូលកន្ទង ស្នេហ៍ស្ងួនឥតក្រែង សេពកាមតណ្ហា ៗ នាងទឹងព្រះអង្គ លើគ្រែ បញ្ចង្គ អែបឱបកញ្ញា ស្តេចសោតថ្នាប់ប្រិន នៅតែកញ្ញា មិនដែល សោះសា នាងខ្មាសពេកពន់ ៗ ខ្មាសអើយពេញខ្មាស នាងខ្ចីស្តេចចាស់ ទ្រង់ទឹងស្រីតន់ ស្តេចគង់ប្រឱប ក្រសោបអនន្ត នាងនាថស្រពន់ ញាប់ញ័រឥន្ទ្រិយ ៗ អស្ចារ្យពេកណាស់ ស្តេចសេពសង្វាស ទឹង នាងនារី នាងមិនសូវធ្លាប់ ញាប់ញ័រសញ្ញី នាងទឹងភូមី ប្រមូលកេគ្នាៗ អស្ចារ្យពេកក្រៃ ផ្គរលាន់សព្ទ ទិសលើមេឃា ផ្កុកបន្ទោរក្លួត ក្លឹ ចាំងមហិមា គ្រុឌចិកនាគា ស៊ីផាបំណី ៗ ស៊ីទ័លតៃថ្អត នាគ ព្រួសពិសផែត ស្តេចទឹងស្រស់ស្រី បរិបូណ៌ស្នេហ៍ស្និទ្ធ ផ្តេកផ្តិតមេត្រី នាងឱនសិរសី បង្គំចមចៅ ៗ បពិត្រព្រះអង្គ ព្រះទ័យទ្រទ្រង់ ព្រះ

គុណាប្អូនពៅ ប្អូនសូមផ្ញើកាយ គ្រាន់បានកក់ក្ដៅ ប្អូនសូមនិត្យនៅ ផ្ញើជន្មជីវិត ៗ តាមតែព្រះអង្គ អាសូរវរវង្ស ជាខ្ញុំទ្រង់បុត្ថិ តាមតែត្រាស់ប្រើ សូមព្រះបតិត្រ ជាគូបូលមិត្ត លុះក្ស័យជីវី ៗ ព្រះអង្គបានស្ដាប់ ពាក្យស្រីចំណាប់ ថ្វាយកាយភូមី ស្ដេចមានដីកា ថាហៃនារី ប្អូនល្អគ្មានពីរ កុំព្រួយណាស្ងួន ៗ បងនឹងប្អូនស្រី គូពីជាតិបានមកជួបជួន លុះសូន្យជីវី ជីវិតរៀងខ្លួន កុំប្អូននឹបន្ទួន ព្រួយកង្វល់យា ៗ សប្បាយទាំងអស់ ពលយក្សឥតខ្ចោះ ខ្ចាប់អង្គពជា ក្រៃមាត្យសប្បាយ កាន់សីលភាវនា នៅក្នុងភាព ឥតមានសៅហ្មង ៗ ស្ដេចគង់និត្យនៅ ស្ដេចក្មួយស្រីពៅ ទាំងពីរទ្ទួនល្អង ក្មួយព្រះបិតាមាតាជាប្រង ដោយសុខក្សាន្ត នឹងឆោមឆើតឆាយ ៗ សូមពោលបារថែង ស្វេះពីតម្ដែង នឹងនាងពណ្ណរាយ នៅនគរយក្ស បានសុខសប្បាយនឹងថ្ងៃពីកាយ នាងនាថកញ្ញា ៗ នាងកេតសុរិយង្គ នឹងនាងអកឹម កើតទឹកកស្ដា យាងទៅយូរពេក មិនឃើញយាត្រា មួហ្ងកាយា នឹងព្រះបត្រិ ៗ ថាឱព្រះអង្គ យាងយូរកន្លង មិននឹកមកស្រីក្មួយសង្សារចាស់ បានសង្សារថ្មី មិនគួរគប្បី ពោលឲ្យនិត្យនៅ ៗ ថាយាងឆាប់មក ឥឡូវពន្ទក ហួសហើយព្រះចៅ មិនគួរសន្យា ធ្វើមិនត្រឹមត្រូវ ពោលឲ្យស្រីពៅ កំព្រាស្វាមី ៗ បើអត់មិនថា តាមតែកសនា ព្រោះឯងគ្មានប្ដី ពេលនេះមានពិត ហើយដូចគ្មានអ្វី មិនគួរគប្បី ជាស្រីមានល័ក្ខណ៍ ៗ ទើបកេតសុរិយង្គ នាងនាថត្រាស់

ត្រង់ នៅអកឹមនាក់ ថាហៃមាសបង ដែលមានចិត្តស្ម័គ្រ យើងទាំង
ពីរនាក់ កំព្រាពេកក្រៃ ។ យើងមានកស្ដា ជួបអត់ទេណា ដែល
នៅសព្វថ្ងៃ គួរយើងទៅតាម ព្រះអង្គបមក្រៃ សូមប្អូនបរៃណា នាង
ជួយគិតបង ។ អកឹមនារី បានស្ដាប់ទេវី ទើបស្ដីសារសង មិនសម
មែនពិត នាំឲ្យម្ហូហ្ង យើងតាមច្បាស់ច្បង នគរគាសុរី ។ ថា
ទៅមិនយូរ វិលមកដោយធូរ គំរប់ឆ្នាំញ ឥឡូវយូរហើយ ខុសសន្យា
ស្ដី ប្រុះនៅត្រើយ ព្រះបងទីងខ្ញុំ ។ នាងកេតសុរិយង្គ បានស្ដាប់
អនង្គ នាងបានឆ្លើយឆ្លង ថាប្អូនគិតត្រូវ ណាកែវទួនល្អង តាមក្សត្រ
ច្បាស់ច្បង ឲ្យដឹងការណ៍ពិត ។ នាងទាំង២កាយ ស្រួលចិត្តខ្វល់ខ្វាយ
តាមព្រះទ្រង់បុត្រ លុះដល់ព្រលប់ ស្រីស្រស់វរមិត្ត សុរិយង្គនាងគិត
នូវកលឧបាយ ។ ឯអកឹមនួន ហៃកែវមាសស្ងួន ចាំស្ដាប់អធិប្បាយ
យើងរត់កុំឲ្យ គេដឹងសព្វសាយ សុខចិត្តស្លាប់កាយ តាមព្រះស្វាមី ។
យើងទៅទាំងយប់ ចូរប្រឹងកុំឈប់ ប្អូនដៀសំដី យើងស៊ូសុខចិត្ត
ត្រេចបរតាមប្ដី បើស្លាប់ក៏ហី តាមកម្មពីព្រេង ។ អកឹមបានស្ដាប់
យកគ្រឿងប្រដាប់ មករៀបតាក់តែង ទាំងពីរអង្គ រូបយ៉ាងបំពែង
យាងយាសស្ទុះស្ទែង ពីប្រាសាទថ្កា ។ មិនឲ្យគេដឹង ស្រីស្នំដេក
ឈឹង ឥតបានដឹងការណ៍ ទីងព្រះទេវិន្ទ ត្រូវជាបិតា មិនដឹងកញ្ញា
លួចរត់ជាម្ដង ។ នាងចំព្រាត់ទៅ ចូលក្នុងព្រៃព្រៅ ទាំង២ប្អូនបង
ក្នុងពេលយប់យន់ ស្ងាបយ៉ាងយំផង ព្រះកំព្រមូហ្ង ដលនេត្រសោក

សៅ ៗ ទុព្រះស្វាមី ថ្មើមចិត្តម្នាស់ប្តី ឲ្យប្អូនមួយមៅ ផ្តែតម្នាក់ឯង គ្មានបានគក់គ្នៅ ដល់ពេលយប់ជ្រៅ ត្រជាក់មហិមា ៗ បើបានព្រះបង គ្រាន់នឹងស្នេហាស្នង មិនស្ងួវរង៉ា ឥឡូវយាងបាត់ ឲ្យប្អូនកំព្រា នឹងព្រះភជា ឥតមានក្បេច ឡើយ ៗ គប់ពេលរាត្រី គ្រាន់បានស្វាមី ស្តេចមកកៀកកើយ ឥឡូវបាត់ស្ងួន ប្អូនទុក្ខឥតស្បើយ ទុព្រះអង្គអើយ មិនមានអាណិត ៗ យាងផងយំផង ពីរនាក់ប្អូនបង ដោយក្តីព្រួយចិត្ត លុះដល់ថ្ងៃរះ ស្រស់កែវវរមិត្រ បួលកន្ទៃព្រៃជិត សម្រាកកាយា ៗ ដោយអស់កម្លាំង នាងខំយាងខ្លាំង បេញពីសេមា បានជាទ្រង់យាង ទៅក្រោមព្រឹក្សា សម្រាកអាត្មា នៅនាដើមព្រៃ ៗ លុះបន្តិចទៀត ស្រស់ស្រីនាងនាថ យាងបរបេញវៃ ឥតមានម្ហូប ដើរតាមក្សេត្រថ្ងៃ បានប្រាំពីរថ្ងៃ ជិតដល់ហើយណា ៗ កាលណោះស្រីស្រស់ ព្រួយចិត្តចំពោះ ក្បៀងផ្គរអស្ចារ្យ នាងកើតម្ហូហ្ម ទាំងពីរកាយា ដេកក្រោមព្រឹក្សា ផ្តុំក្រោមព្រៃធំ ៗ នាងព្រួយចិត្តណាស់ មានផ្គរន្ទះ ព្ធុស្ហូរគ្រំៗ នាងនឹកស្វាមី អាឡៃឧត្តម ដល់ក្សេត្របរមេ ពេកពន់ប្រមាណ ៗ ធ្លូញហើយផ្តុំទៅ នៅក្រោមព្រៃជ្រៅ សម្រាកអង្គប្រាណ សមយេនោះឯង ក្តៅទៅដល់ស្ថាន ទេពទិពពិមាន ព្រះឥន្ទ្រស្ដុគិនាយ ៗ ស្តេចក្តៅអស្ចារ្យ ទេវិន្ទ្រសង្កា ដោយក្តីមិនណាយ ក្តៅអ្វីឯងៗ រកកល់ពុំឆ្ងាយ ទើបព្រះនរាយណ៍ បញ្ចេញញាណញៃៗ បើកចក្ខុទិព្វ ចុះមកក្រោមព្រៃ ទតមើលរំពៃ ឃើញកែវដេរី ទាំងពីរ

នោះនែ ដែលនាងតាមប្តី ដើរតាមដោយដង ៗ ទើបព្រះនាម
ធាយ រៀបព្រះអង្គកាយ ទ្រង់ហោះចុះផ្គង សំដៅកញ្ញា ទៅ
តាមទំនង ហោះដល់ជាមួង ទាំងពេលយប់ជ្រៅ ៗ ដល់ស្រេច
កាលណា ឃើញដួងចម្បា ទាំងគូធំនៅ លោកយកហត្ថា គេះ
ស្រស់ពាលពៅ ជាគីនោមឡៅ នាងតើនសិនសួន ៗ នាងធុំឆ្អើអើ
ចាំស្តាប់សំដី យើងប្រាប់ទៅនួន បូរកែវតើនឡើង នឹងបានជួបជួន
ស្វាមីនៃខ្លួន មិនយូរពេកយពិត ៗ សុរិយង្គជីតា ស្តាប់សូរពាចា ទាំង
ពេលងងឹត គេះអកឹមស្រី ដោយស្លូតក័យកិត ទើបឆ្លើយតតគិត តត
ដឹងសព្វ ៗ ជាចុះម្ចាស់ថ្លៃ យកប្រុងបក្សី មកហៅនៅទី សូមយាង
ចេញទៅ អាណិតនារី ខ្ញុំតាមគូមី ទេព្រះគុណម្ចាស់ ៗ អង្គព្រះ
ឥន្ទ្រា ស្តាប់ស្រីសោកា ទើបឆ្លើយរហ័ស ជាហៃមាសសួន នាង
ស្តាប់ឲ្យច្បាស់ ខ្លួនយើងជាចាស់ ព្រះឥន្ទ្រប្បាកដ ៗ យើងឃើញ
នាងស្រី ចំដើរតាមប្តី ព្រួយព្រាណហាបហត់ យើងចុះមកជួយ ដល់
ថ្លើមស្រីរត្ន ឲ្យនាងកំណត់ បានសុខសិរី ៗ ហេតុនេះបូរសួន ស្តាប់
ឲ្យចាំមួន នាងកុំខ្លាចអ្វី យកបំពៀននេះ ពាក់តាមស្វាមី ទាំងពីរ
ប្រឹមប្រិយ កុំខ្លាចអ្វីឡើយ ៗ ទឹងក្លាយអាត្មា ជាកូនយក្សា សឹង
សួនបានស្បើយ មាសដៀយើងចុះ ណាស្រស់កែវអើយ យើងឥត
ភឡើយ ដោយពាក្យសច្ចៈ ៗ នាងនាថបានស្តាប់ ត្រេកអរចំណាប់
បង្គំទ្រង់លក្ខណ៍ គោរពទាំង២ យកបំពៀនពាក់ ត្រេកអរស្មោះ

ស្រ្គ៏ ដល់ព្រះបរមត្រៃ ៗ លោកឲ្យជម្រង៏ ឫទ្ធិកើតកន្ទង៏ ឲ្យដល់
បរិណា បើមានសត្រូវ យារយើកង៏ត្រៃ ឲ្យជម្រង៏រ៉ៃ សម្រាប់ដោះ
ទុក្ខ ៗ បើមានសត្រូវ យារយើស្រីពៅ នាង៏កុំយល់មុខ វាយនឹង៏
ជម្រង៏ ឲ្យឃើញធាប់ធុត បានបួបបមមកុជ ស្វាមីស្រីស្ងួន ៗ នាង៏
សោកបានស្តាប់ អវត្រែកចំណាប់ នឹង៏ព្រះគោមស្ងួន លើកហត្ថទាំង៏
ពីរ បង្គំមាំមួន ដោយលាភមកជួន មកជួបតន្រ្តា ៗ កាលនោះ
ទេវិន្ទ ឲ្យទៅមាសផ្ទឹន ហើយអង្គទេព ទ្រង់យាង៏ហោះបញ ឥត
មានរុញ្ញរា ដល់ស្ថានសួគ៌ា សេពសោយសុខា ៗ ថ្ងៃង៏ពីនាង៏នាប
ទាំង៏ពីរនេះទៀត នៅក្រោមព្រឹក្សា បានជម្រង៏ជ័យ នឹង៏បំពេញថ្វា
ក្លាយរូបធិតា ដាយក្សហើយនៃ ៗ យក្សទាំង៏២ប្រាណ លុះព្រឹក
បវថ្កាន ឥតមានទុក្ខភ័យ ចំគោបរទៅ សំដៅទីថៃ ដោយបុណ្យ
និស្ស័យ ដល់បុង៏សេចា ៗ នាង៏យក្សទាំង៏ពីរ ចូរអៃបគិរី កុង៏ទី
បត្តា សម្រាកព្រះកាយ ឲ្យបាត់ទុក្ខា ស្ទះលែង៏បវបា ត្រង់នេះ
ជាមួង៏ ៗ នឹង៏ថ្ងៃទៅអង្គ ពង៏ព្រោធវរវង្ស សុវណ្ណហង្សប្រាស់
បង្រ៏ ថ្ងៃនោះព្រះអង្គ ស្តេចទ្រង់មូហ៊ង៏ ដោយបុណ្យព្រេង៏ចង៏ ជួប
នឹង៏មហេសី ៗ ទ្រង់កើតវិតក្ក ព្រះកាយអផ្សុក ទើបលោមប្អូនស្រី
នាង៏កមល្ងកា កែវសង៏ក្រថ្មី ហៃប្អូនប្រិមប្រិយ ប្រាណបង៏សុំលា ៗ
ទៅលេង៏ព្រឹកព្រៃ កំសាន្តព្រះទ័យ ណាស្រស់ស្ងួនភ្ងា លុះដល់ព្រ-
លប់ ជួបចូលសន្ធិយា បង៏វិលមីមា មករកប្អូនទៅ ៗ នាង៏សោក

បានស្ដាប់ ស្ដេចផ្ញើត្រូវច្បាប់ នាងមិនហ៊ានសៅ ថាយាងទៅចុះ ខ្លួន
ប្អូនទិត្យនៅ តែសូមព្រះចៅ ឆាប់វិលវិញក៏ ។ ស្ដេចបានស្ដាប់ហើយ
នៅនាងត្រាណត្រើយ ទ្រង់មានទុក្ខា ហៅអស់សេនី គាល់មីរត្រៀប
ត្រា អុីយសេនា ជូនអញទៅព្រៃ ។ ពលយក្សបានស្ដាប់ ដោយ
ធ្លាប់ដឹងច្បាប់ រៀបរថអាជានេ័យ គោរមាំងសេះ ច្រើនណាស់ទាំង
រូបហើយឥតភ័យ ទូលក្សត្រាឆាមឆាយ ។ ថារៀបហើយនៃ សូម
ទ្រង់កុំភ័យ គ្រឿងរថទាំងឡាយ បរិបូណ៌គ្រប់សព្វ សូមយាងប្រាណ
កាយ ឆាប់យាងសប្បាយ ទៅក្នុងព្រៃព្រឹក្ស ។ ស្ដេចយាងចុះទៅ
ពលយក្សគាល់នៅ ចុះហៃរគគឹក សំដៅយាត្រា ឥតអាក់ឥតក្អឹក
ពលតាមសន្ធឹក យាងតាមមាគ៌ា ។ ចេះតែចេញទៅ ព្រះអង្គបម
ចៅ គ្មានព្រួយអង្គា ដល់ក្នុងបព្វតា ទតព្រៃនានា កំសាន្តទយា នឹង
អស់ពលផង ។ បេះផ្លៃផងនៃ កំសាន្តព្រះទ័យ ពលក៏អឹងកង មក
ប្រែងម័កប្រាជ្ញ ថ្វាយហើយស៊ីផង សប្បាយកន្ទង ក្នុងព្រៃនោះឯង ។
ថ្ងៃពីរយក្សស្រី ដែលជាមហេសី គិតពិតយក្សក្លែង ព្ធមាត់អឹងកង
នាងឥតបម្រុង ថយពីកន្ទុង លបមើលដើងការណ៍ ។ ដោយព្ធ
ស្វរយក្ស ច្រើនក្រអទ័ក្ស បានជាសង្កា ទើបនាងមើលទៅ ឃើញ
អង្គក្សត្រា ត្រូវជាកស្ដា នាងទួនកល្យាណ ។ ទើបកេះខ្សឹបខ្សៀវ
ប្រាប់ថាដំណារ ហៃប្អូនកុំផាន កែវមើលទៅចុះ នោះហ៊្នក្សត្រក្រាន្ត
គង់តែឯកប្រាណ នៅលើហត្ថី ។ ប្អូនឯងមើលចុះ ព្រះបាទទ្រង់

យស បានសន្ត្រាវថ្មី ក្មេចសន្ត្រាវចាស់ ចិត្តប្រែសពីរបី ទុកើតជាស្រី
កម្សត់អភ័ព ៗ គេបេះយកបាន ស្រី៣-៤ប្រាណ ញាតិគេនៅរាប់
ឯងក្បត់តែមួយ គេទុកដូចឆាប់ ពិតជាស្អុយជាប់ អស់រយខែឆ្នាំ ៗ
ទើបនាងយកកូន ស្រុះពីកន្ទេង ដោយក្តីនាងចាំ ទៅឧបបាទ ពោល
កូនតាមកម្ម កូនពាក្យសសាំ កូតកនោមយំ ៗ បពិត្រព្រះគុណ
អាណិតប្អូនតន់ ប្រសើរមានទ្រង់ ខ្ញុំកូនយកក្សា វេទនាយូរលង់ បិតា
បមពង្ស គេសម្លាប់ក្សយ ៗ ខ្ញុំរត់រួចខ្លួន មកពីនាក់ប្អូន មកពឹង
បមត្រៃ សូមទ្រង់អាណិត ជួយគិតកែខ្ញុំ ធ្វើខ្ញុំក្សត្រថ្ងៃ លុះសន្យ
ជីវី ៗ ព្រះអង្គបានស្តាប់ យកក្រកូនសារសព្ទ ថ្វាយដល់ភូមី ទ្រង់
មានព្រះទ័យ អាណិតនារី ទើបទ្រង់សម្តី ស្នេហាយកក្រនោះ ៗ
ទើបច្រាប់សេនា ឲ្យមើលកញ្ញា ពីរហ្នឹងចំពោះ ទុកដូចបុត្រី បក្រ
អនុគ្រោះ បានហើយទ្រង់យស មានព្រះឱង្ការ ៗ ស្នេហ៊ុយសេនី
ចូលវាំងបុរី នាំដួងសុជា ដៀតថ្ងៃរសៀល ទន់ព្រះសុរិយា នាំយក្ស
កញ្ញា ចូលបុរីរដ្ឋ ៗ ពលផងមិនយូរ ប្រុងឥតមួរទូ ខាងព្រះចក្រ-
ពត្តិ រៀបយានជំនិះ សំដៅទៅរដ្ឋ នាំព្រះមហាក្សត្រ ចរចេញ
កន្តើយ ៗ យាន់ពីព្រឹកព្រៃ លុះយប់ហើយនៃ ដល់ក្រុងត្រាណត្រើយ
សឹងបានសុខកាយ ឥតមានទុក្ខឡើយ ចូលអែបបម្តើយ [illegible]សីជីវិត ៗ
ឯបទឹងកមល្ហុកា ទើបទ្រង់ស្តីថា ហៃកែវមាសស្និទ្ធ [illegible]ទៅក្នុងព្រៃ
មានលាភពេកពេក យកស្រីនោះស្និទ្ធ ជំងឺមកពីណា ៗ មកសូម

ផ្ញើខ្ញុំ ថាកើតទុក្ខធំ ព្រាត់អស់បិតា បងអាណិតក្រៃ នាំបួលរក្សា ទុក
កែវស្នេហា ជាបុត្រគលក្ខណា ៗ នាងនាថបានស្ដាប់ មួហ្នងបំណាប់
តែស្រៀមក្នុងប្រាណ មិនហ៊ានបន្ទោស ផល់ទោមទ្រង់ញាណ នាង
មិនរិះធ្យាន ថាតែអ្វីឡើយ ៗ លុះដុំនិត្យនៅ នឹងអង្គព្រះទៅ រួម
រក្សកៀកកើយ នឹងអង្គទេវិទូ ផ្ទុំលក់ល្ងឹងល្ងើយ ស្រមុកឡើយ ៗ
ទាំ តីរទោមធាយ ៗ ថ្ងៃងពីនាងយក្ស ទាំងពីរអន្ទក្ស មហេសី
ក្លែងក្លាយ ចរចូលប្រាសាទ ទៅឃើញពណ្ណរាយ ផ្ទុំឯបមិនឆ្ងាយ ពី
កាយកមល្ងកា ៗ ត្រឹព្រួចក្នុងចិត្ត ចង់ស្ទុះទៅឃិត នៅលើមញ្ចា
ចុកណែនដើមទ្រូង មហេសីក្រឡា ញាប់ញ័រអាត្មា ស៊ើរទប់ពុំបានៗ
ថាមើលម៉ែនេះ ផ្ទុំនឹងដោមម្ទះ មីចោរតិរច្ឆាន ហ៊ានលួចប្ដីអញ មក
ផ្ញើបែបក្បាន្ត ឲ្យអញរំខាន សត្វសាប់សញ្ញី ៗ នាងកេតសុរិយង្គ
នឹងកែវវិវង្ស អគ្គីមនារី កើតក្ដីហ្មងសៅ ញាប់ញ័រឥន្ទ្រិយ ប៉ុន្តែទេ-
វី ទប់ព្រះទយា ៗ មើលទៅនាល្ងង នាស្ពានគន្ទង ដែលព្រះ
រាជា ឲ្យផ្ទុំនិត្យនៅ ពេញសែនកំព្រា ព្រួយប្រាណមហិមា សៅ
ហ្មងក្នុងចិត្ត ៗ លុះព្រឹកសុរិយា ពន្លឺផ្ទះថ្វា កំចាត់ងងឹត នាង
យក្សទាំងពីរ ព្រួយប្រាណពេកពិត អង្គុយបែបគិត កិច្ចកលអ្វី ៗ ៗ
ថ្ងៃងពីកមល្ងកា តេនចាកក្រឡា នឹងអង្គចក្រី ពុំសុខសប្បាយ ឥត
មានទាស់អ្វី ទើបនាងស្រស់ស្រី កមល្ងកាសាមាន្យ ៗ ហៅយក្ស
ខ្ទេហា ទៅប្រាសាទថ្វា ឲ្យបម្រើប្រាណ គក់ជើងគក់ដៃ ឥតប្រ

ណីព្រាណា ឥតមានឡើយខាន កាលពេលជាម្ដង ៗ ថ្ងៃមួយនោះណា
ឲ្យផ្ទុះមំសា កមល្វកានួនល្អង នាងផ្ទុះឲ្យទៅ មិនស្រួលកាយខ្លួន ដេរ
ឥតទំនង ថាមីយក្សព្រៃ ឲ្យមកចូលក្រុង សសើតសស្លុង មិនដឹង
ទីទៃ ផ្ទុសមិនស្រះទេ មីយក្សបង្រៃ ហង់នៅព្រឹក្សព្រៃ ទើបបានវា
សម ៗ ឲ្យមកនៅក្រុង ខាងក្រៅខាងក្នុង ឥតបេះរៀបចំ មីចោរ
មុខប្លុក កើតឥតប្រទាំ ប្ញះព្រះបរម យកត្រើបុត្រ ៗ នាងយក្ស
បានស្ដាប់ កមល្វកាសាសព្ទ ដេរដៀលនួនស្រី នាងខំអត់ណាស់
មិនពោលពីអ្វី ស្រស់កល្យាណី យកតែពីសុខ ៗ ដេររួចហើយ
ណា ចូលក្នុងប្រាង្គប្រា យក្សតីរកើតទុក្ខ ក្ដៅនឹងកមល្វកា ដើមទ្រង់
ចាប់បុក ដោយក្ដីចង់សុខ ខំទ្រាំនិត្យនៅ ៗ ថ្ងៃងពីក្សត្រា ឃើញ
ពីរយក្សា ព្រះអង្គចមទៅ សែនសង្ស័យណាស់ សម្ដេចក្រអៅ ដូច
ជាស្រីពៅ សុរិយគ្គទេវី ៗ មួយដូចអកឹម ទាំងពីរ ៗ នឹម សម
ក្រៃនារី តែស្ដេចនៅស្ងៀម បេះតែសំភី អង្គព្រះភូមី រក្សានួនល្អង ៗ
បំណីបំណុក ឲ្យគេចាប់ទុក នាងសោយទាំងសង មិនឲ្យមានភ័យ
បានសុខក្នុង ទាស់តែនួនល្អង កមល្វកាត្រាណត្រើយ ៗ

## បទពំនោល

ក្សណានោះសុរិយគ្គថាថ្ងៃ ព្រួយព្រះទ័យក្រៃ ទើបស្ដេចទៅកាន់ស្រី
ហើយ ៗ ហៃនែអកឹមត្រាណត្រើយ យើងកុំនៅឡើយ នាំកើតសៅ-
ហ្មងក្នុងចិត្ត ៗ កមល្វកាមីនេះឯងពិត មីចោរទ្រស្តមិត្ត វាហ៊ានក្បត់

យកស្វាមី ៗ ធ្វើគ្រាន់ហើយមកជេរស្តី មេថោរគាឡី ព្រហើន
ហ៊ានជេរយើងណា ៗ ចេះយើងតែងជាអគ្គភ ទុកឲ្យកស្តា យើង
ជឹងកិច្ចកលឧបាយ ៗ គិតក្លាមស្រីតាំងពីរកាយ ប្រឹងតែងខ្វល់ខ្វាយ
តាមដោយបញ្ញាស្រស់ស្រី ៗ យកមកបិទក្លោងទ្វារជ័យ ពេលយប់
នោះនៃ បរិណនាងចេញយាត្រា ៗ សុរិយគ្គស្រីស្រស់កញ្ញា នាង
នាងប្រាប់ថា ហៃនៃអកឹមធោមធាយ ៗ ប្អូនអើយបើយើងថ្ងៃងកាយ
នាំកើតអន្តរាយ សៅហ្មងពីព្រោះតាមប្តី ៗ ណ្ហើយចុះតាមកម្មជាតិ
វិលទៅបុរី នៃអែយត្រូវផ្លូវមគ្គ ៗ យើងទុកសំបុត្រជាធំ ឲ្យព្រះឧត្តម
ស្តេចទតសព្វសារសន៍នេះម្តង ៗ ស្តីស្រេចស្រីស្រស់ទងរង យាងតាមទំ-
នង បរបេញតឹកពសីមា ៗ គួរឲ្យអាសូរកញ្ញា ទំប្រឹងយាត្រា សំ-
ដៅទៅចូលព្រៃព្រឹក្ស ៗ តែចិត្តនាគនាំទឹក សង្វៃសន្ទឹក ដល់អគ្គ
ធោមធាយក្លូមី ៗ ត្រាប់ដើរកាត់អស់គីរី ក្លូចអស់ទិសទី ទឹកនេត្រ
នាងហូររ៉ៃៗ ៗ នឹកដល់ព្រះមុនិន្ទបមត្រៃ គឺជាទិស្ស័យ ឲ្យព្រាត់
ព្រះបាទស្វាមី ៗ នាងទំត្រាច់យាងពីរស្រី គួរឲ្យប្រណី ដល់ស្រស់
បវរមាសមិត្រ ៗ ខ្លួនស្រីទំយាង់ឥតគិត ប្រាំពីរថ្ងៃពិត ចូលទៅក្នុង
ដែនសីមា ៗ នាងដោះបំពាក់នហាត្ម កក្លាយជាត្មា ល្អមេតដូច
ដើមប្រាកដ ៗ លុះដល់ព្រៃរាប់រាត្រ យាងតាមបែបបទ ទៅដល់
ប្រាសាទពាជា ៗ សម្តេចសុធនកុមារ ព្រមទាំងសុនក្លា ដែលជា
មហាសីធោមយន់ ៗ ទៅបាត់មិនឃើញយូរលង់ ឥឡូវអនង្គ នាង

ឡប់មកទាំងទ្វេហា ៗ ហៅសួនទឹមទួនបិតា . នាងមកពីណា ឲ្យប៉ូវ
កើតក្តីវិទាន ៗ ចិរកកម៉ិនដឹងដាន ឲ្យគូនកល្យាណ ចូរថ្លែងប្រាប់
មកកុំលាក់ ៗ នារីទេវីស្តាប់ជាក់ ឲ្យទាំងពីរនាក់ កាយកាច់ដំណើរ
ដើមទង ៗ ពោលដូចដើមឃ្លានោះផង ថ្វាយក្សត្របង្រាស់ប្រង ដូច
មាននៅខាងដើមឃ្លា ៗ ស្តេចជ្រាបនៅក្នុងទយា ស៊ើបបិត្តពុំជា ទិ
ប្រឹងយាត្រាតាមប្តី ៗ រួបហើយស្រស់កល្យាណី បង្គំវរបី យាងទៅ
ប្រាសាទសាន្តសុខ ៗ គ្មានភ័យប្រឹមប្រីយផុតទុក្ខ សុំផងគុក បម្រើ
នារីរវេរជាស ៗ ដោយទឹកនាងយូរខ្វាំងណាស់ ឲ្យនរបីបាទម្ចាស់
គោរពគតមានឲ្យល្អង ៗ ត្រង់ណោះឈប់ស្ទះជាមួង ទីងពោលសារ-
សង ពីពោធិសត្វកើតឆាយ ៗ នៅនគរយក្សនោះឆ្ងាយ ក្រៃមាត្យ
បុទ្ធិសាយ រូបរូមកមល្លិកាទេវី ។ ព្រះអង្គតោមធាយភូមិ ទ្រង់បាត់
យក្សពីរ កំកើតមួហាងពេកតាន់ ៗ ទ្រង់យាងរកគ្រប់ដំបន់ ក្រៃង
ឃើញបូនគន់ នាងនៅទាំងពីរនោះនៃ ៗ ដោយពុំដឹងជាមហេសី
តែទាស់សំដី ប្រហែលមកជាយូរយា ៗ ស្តេចរកលុះដល់ក្បានគ្វារ
ឃើញសាសន៍ពិរា ចិទនៅទីនោះហើយហោង ៗ ស្តេចទតដឹងគ្រប់ជាមួង
ពាក្យពោលសារសង ដូចបានចារថែងថ្លែងថា ៗ នាងខ្ញុំទាំងពីរទេ្វ-
ពោ សូមឲ្យនសិរសា បង្គំដល់រាជស្វាមី ៗ សុរិយគ្គទីងអកមស្រី
បូនសូមលាប្តី ទៅអែយតេ្រវិញហើយ ៗ ជ្រុតប្អូនមកតាមត្រាណា-
ត្រើយ ស្តេចនៅត្រាងើយ យកប្អូនធ្មើបុត្រសោភ័ណ ៗ ប្អូននៅកមល្លិកា

ជិះជាន់ វាធ្វើឫកគ្រាន់ មីហោរក្រត់ល្អបព្តីគេ ៗ វាដឹងថាខ្ញុំនេះនៃ ព្រះអគ្គិនោមស្នេហ៍ អាសូរករុណាខ្ញុំផ្ទាត់ ៗ មេនេះព្រះហ៊ុនពេក ក្តាត់ ឲ្យខ្ញុំប្រតិបត្តិ បម្រើខ្លួនវាអស្សារ្យ ៗ ដេរស្តីខ្ញុំឥតមេត្តា ដោយ វាគាំងថា ខ្លួនខ្ញុំនេះជាយក្សព្រៃ ៗ ដេរដៀលសត្វគ្រឿងទីទៃ បាន ជាខ្ញុំលៃ ទ្រាំនៅពុំបានជាមួយ ៗ ប្អូនសូមគោរពព្រះបង យាងកុំ យូរហោង អាណិតសង្វារកំសត់ ៗ ហើយយកកម្លូកាស្រីរត្ន ទៅ កង់ស្នានសិត ឲ្យប្អូនបានស្គាល់មុខវា ៗ ប្អូនខំដើរតាំងកំព្រា ប្តូរតាម វាជា សុខបិត្តស្ងាប់ដន្ទមិនស្តាយ ៗ ហេតុនេះប្អូនណាធោមធាយ តែងមិនក្រោះក្រាយ សារខ្លួនខ្ញុំនេះជាស្រី ៗ ព្រះអគ្គទតបប់សឹដី អាសូរពីសី ញាប់ញ័រទាំងអគ្គកាយី ៗ ពោកខ្លួនថាឱទេវី មិនឲ្យ ក្ងមី បានជ្រាបពីកិច្ចយោបល់ ៗ បើប្អូននាងហ៊ានមកដល់ មិនគិត ពន្យល់ ឲ្យបងដឹងថាប្អូនស្រី ៗ ដល់ហួសបាននាងប្រាប់ប្តី ទើបព្រះ បក្រី យាងចូលទៅជួមហាង ៗ ទឹកនេត្រហូរហ្វូងគន្លង ទឹកដល់ទួន ល្អង ដែលនាងត្រាត់ប្រាសបាត់ទៅ ៗ បេះតែទ្រង់ពោកសោកសៅ ទើបនាងស្រីពៅ កម្លូកាមតស្នូរទ្រង់ឫទ្ធិ ៗ ថាហៃបមមកុជជីវិត ស្តេចកើតភ័យកិត ប្តូមួយមានទោសទយា ៗ ទាសាទាសីនានា ប្ត ប្អូនពាំនាំ ធ្វើទាស់ក្រោមល្អងធូលី ៗ សូមប្រាប់កំលាក់នារី ឲ្យដឹង ដើមទី តើមានទោសធ្ងន់ពីអ្វី ៗ កាលស្តេចបានស្តាប់នាងស្រី ទ្រង់ ធ្វើយតបខ្ញី ថាហៃប្អូនឥតខុសឡើយ ៗ យក្សស្រីតាំងពីគ្រាណ-

ក្រោយ រត់បាត់ទៅហើយ មិនឃើញនៅក្នុងសេមា ៗ បងនឹកអាណិត

អស្ចារ្យ បានជាសោកា អាសូរផ្ដាយព្រាត់ប្រាសក្រៃ ៗ ហេតុ

នេះប្អូនកុំសង្ស័យ គឺក្ដីអាល័យ នាងនាថទាំងពីរនេះឯង ៗ នាង

ស្ដាប់សម្ដេចតម្ដែង នាងឥតចម្លែង ដឹងថាប្រែបំលមហេសី ៗ បើ

មិនមែនទេយំអ្វី ឡោចមីយកស្រី ខ្វះណាស់នៅពេញសេមា ៗ

ទើបនាងស្រស់ស្រីទូលថា សូមប្រាប់កិច្ចការ ប្អូនដឹងពិតជាមហេសីៗ

ប្រកុំលាក់នឹងប្អូនស្រី ណាព្រះស្វាមី ទ្រង់ពោលឲ្យត្រង់មកចុះ ៗ

ព្រះអង្គបានស្ដាប់បំពោះ ទើបព្រះទ្រង់យស លួងលោមព្រលឹងទៅ

ថា ៗ ប្អូនអើយនាងកុំសង្កា ប្រស្ងួនមេត្តា អាណិតដល់បងព្រ-

លឹង ៗ ដ្បិតនាងទាំងពីរយក្ខិនី ប្រប្អូនត្រូវដឹង ពិតជាមហេសី

បងហើយ ៗ នាងខ្ញុំមកតាមតុំស្បើយ ហៃសង្សារអើយ នាងកុំ

ប្រកាន់ទោសពៃរ៍ ៗ នាងនាថបានស្ដាប់ក្រី ទ្រង់កើតភិតភ័យ

ដោយខ្លួនធ្លាប់តុំងា ដ្បិតនាងតុំដឹងសោកា ស្មានហាក់ដូចថា យក្ស

ពៃព្រាកដនេះឯង លើកហត្ថបង្គំទោមសេរី ទូលព្រះគម្ដែង ខ្លួនប្អូន

មិនដឹងសោះឡើយ ៗ បើដឹងពិតតុំកន្ដើយ បង្គំក្រាណក្រោយ តាម

ខ្លួនជាស្រីបុំគេ ៗ ប្អូនមិនធ្លើបពាន់ទេ សូមព្រះធោមស្នេហ៍ អនុ-

គ្រោះបំពោះនាងខ្ញុំ ៗ ទើបស្ដេចថាហៃមាសម៉ុំ រឿងនេះមិនសម យក

ទោសនរណាបានផង ៗ ណ្ហើយចុះកុំគិតនាំហ្មង បងលាខ្លួនល្អង

ទីងទៅក្នុងកដបុរី ៗ លាទៅគំរប់ឆ្នាំ៣ ទីងវិលវិញខ្ញុំ មកក្រុងសេមា

នេះវិញ ៗ ហេតុនេះប្អូនសម្លាញ់ កុំពៅទុក្ខម្នេញ ស្តាប់ភជ-
ទុក្ខារណាពៅ ៗ នាងទូលថាខ្ញុំមិនទៅ សូមតាមព្រះចៅ លុះសូន្យ
ជីវិតប្អូនស្រី ៗ ស្តេចក៏ទ្រង់សុវណ្ណី ថាប្អោះចុះជី យើងទៅសូម
លាបមកត ៗ បិតាមានបុត្រលើសលប់ យើងបូលគោរព សូមលា
ទៅអយុត្ថណា ៗ ស្តីក្ដាមយាន់កាន់ហត្ថា នាំប្អូនដ៏ព៌ ឡើងប្រាង្គ
ប្រាសាទអសុរី ៗ បង្គំដល់បមកតាត្រៃ ថាសូមព្រះបី ផ្ដាប់ទូលកល់-
កិច្ចឧបាយ ៗ កូនមកសូមលាពន្រាយ ទៅនគរនាយ ដោយនឹក
រលឹកបិតា ៗ បានជានាំនាងកញ្ញា ចរចេញយាត្រា យាងទៅក្នុង
ពេលនេះឯង ៗ ក្រៃមាត្យបមមកុដស្តេចស្តេង ស្តាប់កូនថាថ្លែង កំ
មានព្រះទ័យម្នុហ្ន ៗ ទើបឆ្លើយដោយតាមទំនង ហៃកូនបក្សប្រង
អ្នកទៅឆាប់វិលមកវិញ ៗ កុំឲ្យប្អូនកើតទុក្ខម្នេញ ប្អូនពៅសម្លាញ់ អ្នក
ទៅកុំឲ្យយូរយា ៗ ដ្បិតប្អូនកាន់តែជរា ព្រួយព្រាណមហិមា សង្ឃឹម
តែលើកូនស្ងួន ៗ ហេតុនេះទៅហើយនឹមនួន ពៅឆាប់វិលខ្លួន មក
ក្រុងបុរីសមា ៗ ស្តេចស្តាប់ព្រះភជទុក្ខារ ក្រាបទូនអាត្មា បង្គំលា
អង្គបមាត្រៃ ៗ ទើបហៅអស់ពលសេនី ឲ្យមើលបុរី ការពារសត្រូវ
តាំង-ឡាយ ៗ ស្តេចយាងមិនយូរឆាប់ខ្លាយ ខ្វល់មកទីកាយ រក្សា-
ព្រស្ត្រផងឲ្យសុខ ៗ ស្តីហើយដោមឆាយប្រមុខ នាំកែវទ្រលុក ចេញ
ពីបុរីយាងទៅ ៗ ពីរគាយសប្បាយតាមផ្លូវ បេះតែសំដៅ នគរឯយ្យ-
រត្ថា ៗ ដោមយន់ចំប្រឹងអស្ចារ្យ ឃើញមានស្រះថ្មា នៅក្បែរ

ផ្ទូវផ្កានោះឯង ៗ ស្តេចនាំស្រីទៅស្រង់លេង ហែលទឹកទន្ទេង
សប្បាយរកប្រៀបមិនបាន ៗ ទ្រង់ហែលលោលោតតាញព្រាន នឹងកែវ
កល្យាណ ទ្រង់ព្រះសម្រួលក្អាកក្អាយ ៗ ទាំងពីរហែលពេញ
សប្បាយ សម្រួលក្អាកក្អាយ នឹងកែវដ៏វិប្រិមប្រិយ ៗ ស្រង់រួច
យាងឡើងមកក្តី រៀបកាយចក្រី សំដៅគោចរទៀតហើយ ៗ
សប្បាយគ្មានមួយឃ្លាងឡើយ ទាំង២ត្រាណត្រើយ លុះដល់ពេលបស្ទ្យាៗ
ចមមកុជនាំស្រស់ពុំងា ផ្ទុំក្រោមរុក្ខា តាមដោយព្រះរាជហឫទ័យ ៗ
សប្បាយឥតមានភិតភ័យ ទាំងពីរនោះនៃ បានសុខសប្បាយក្នុង ៗ
ស្តេចឱបទងស្រស់នួនល្អង អង្អែលទងវង់ បំពេឲ្យផ្ទំលក់ទៅ ៗ
ស្តេចក៏ផ្ទំលក់គ្មានទៅ ទាំងប្អូនពាលពៅ លង់លុះព្រះសុរិយាងថែង ៗ
ទើបព្រះនរិន្ទថ្កែង យាងឥតខ្លាចក្រែង នាំប្អូនចរលេលា ៗ លុះ
បានប្រាំពីរទិវា ដល់បុងភាព ព្រះអង្គស្គាល់ជាក់ហើយនៃ ៗ ក៏
យាងឥតមានភិតភ័យ ដៃឆ្នៀសស្នួជ័យ គគីកព្រៃមីរក្រៃក្រាស់ ៗ
ដោយអង្គយាងបាត់យូរណាស់ ពស្ត្រីលើកម្ចាស់ ដៃផ្ហឹងកងធឹត ៗ
សប្បាយកាយព្រះទ្រង់ឫទ្ធិ ឥតមានភ័យភិត លុះទៅបានដល់ប្រា-
សាទ ៗ បិតាមាតានរនាថ ឡើងក្រោបអភិវាទ ទាំងពីរបង្គំក្យត្រៃថ្ងៃ ៗ
ស្តេចទតឃើញបុត្រចរណៃ ដោយនឹកអាល័យ ញញឹមហើយស្ទួរទៅ
ថា ៗ កូនប្រុសបុះនាំរង្គា ក្រុងនៃយក្សា សុខទុក្ខដូចម្តេចចូរថ្លែង ៗ
ព្រះបុត្រប្រសានេះឯង នាមសីល្អខែន ចូរប្រាប់កុំយូរឡើយហោង ៗ

ស្ដេចស្ដាប់បិតាច្បាស់ប្រាប់ ពោលតាមទំនង សុខទុក្ខទាំងឡាយឥត សល់ ៗ ថ្វាយដល់ទេវិទូទសពល ស្ដេចជ្រាបចុះសព្វគល់ ដូចបាន ពោលខាងដើមឃ្លា ៗ ហើយប្រាប់ព្រះនាមពុំគា ឈ្មោះនាងកមលូកា ជាកូនក្រៃមាត្យផោមយង់ ៗ ហេតុនេះសូមព្រះមានទ្រង់ ជ្រាបតាម ទំនង ដែលកូនបានពោលនេះហើយ ៗ ស្ដេចស្ដាប់អរពុំមានស្បើយ ស្នេហ៍កូនត្រាណត្រើយ ក៏ឲ្យទៅប្រាសាទថ្វា ៗ ថាកូនទៅចុះនៃបា ទៅជួបគញ្ញា ទឹងកែវសុរិយគ្គពាលពៅ ៗ ទឹងអកឹមស្ងួននិត្យនៅ ហេតុនេះចូរទៅ ថ្វ្រធាប់កុំឲ្យមួហ្មង ៗ ដ្បិតនាងសោកាកន្ទង់ ទៅ កុំយូរហោង ដ្បិតគ្នាទឹកកូនណាស់នៃ ៗ ស្ដេចស្ដាប់បិតាអភ័យ នាំ ស្ងួនចុះវាំ សំដៅប្រាសាទខេតធាយ ៗ ស្ដេចយាងទៅដល់ព្រៃយកាយ ឃើញទេព្ទណ្ណពយ បង្អួលមករកកមលូកា ៗ ស្ដេចព្រៃយក្រៃកើត គោលាហ៍ សន្ទុះធីតា ទាំង២មិនដឹងដូចម្ដេច ៗ ឡើងទៅដំណាក់ រំពេច នាងពីរកើមិច ក្អែកបង្អួលនាងកមលូកា ៗ សុរិយគ្គស្ទុះក្ដាម ផេរថា រុំយមេសារ៉ា ហងឯងហ៊ានលួចប្ដីអញ ៗ អញទៅហង់ត្រើ ទុក្ខម្ទេញ ដៀលផេរបណ្ដេញ ឲ្យអញមួហ្មងពេញក្ដៅ ៗ ហងឯង ចូរប្រយ័ត្នទៅ សៀងណាស់កុំនៅ ចេញពីប្ដីអញឲ្យផាប់ ៗ អកឹម ក៏ស្ទុះចំណាប់ ផេរថាសារសត្វ ថារុំយម៉ៅចោរសាមាន្យ ៗ ហងឯង បានសមគិរប្ញាន នោះទើបសមប្រាណ ម៉ៅចោរជកទង់អបលក្សណ៍ៗ ព្រួតជេរគ្នាទាំងពីរអ្នក ទើបព្រះបមបក្រ ថាឈប់កុំទាស់គ្នាអ៊ី ៗ

បូរស្ងួននាង ស្ដាប់ពាក្យប្ដី ពាស់តែប្រិមប្រិយ ប្អូនស្ងួននាងក្រុងកាយា ៗ
ស្ដីហើយទើបប្រាប់កមល្យកា ហៃដួងសុជា បង្គំសូមទោសគេទៅ ៗ
ផ្សិតប្អូនប្រែពន្ធុបុងនៅ ណ្ហើយបុះមាសនៅ យើងត្រូវមានចិត្តសាមគ្គា ៗ
កមល្យកាស្ដាប់ហើយវន្ទា បំពោះសោភា សុរិយគ្គទីងអភិមស្ងួន ៗ
សព្វគ្រប់ទៅតាមចំនួន សុរិយគ្គក៏ជូន ព្រះទ័យកំទទនស្នេហ៍ស្និទ្ធ ៗ
ទាំងពាស្នេហ៍អស់ពីចិត្ត បានរួមមូលមិត្ត ទាំងពាលែងពាស់គ្នាហើយ ៗ
ថ្ងៃងពីបមមកុជគ្រាណាត្រើយ ព្រះអគ្គបានស្បើយ ដោយស្ងួនបានសុខ
សប្បាយ ៗ ស្នេហ៍ស្និទ្ធនៅទាំងពាកាយ ត្រល្បីសុសសាយ ខ្ចាប់
ព្រះបមមកុដពេកពន់ ៗ សប្បាយទាំងទិសតំបន់ ដោយអគ្គទោមគន់
ទេះប្រើទន្ទូវកលឧបាយ ៗ

## បទកាកគតិ

ត្រង់នេះឈប់ស្ទុះ ថ្វាថ្ងៃតាមទេះ ពីយក្សទោមទាយ មាន ប្អូនបារមី ប្រសើរពណ៌ពាយ យក្សផងទាំងឡាយ ខ្លាចអាសុរ ៗ នាមវិរុឡ្ហមេឃ ប្រសើរពន់ពេក ល្បើលើទ្វីបា ជាស្តេចយក្សឯក អ្នក មានចេស្ដា នៅតែឯកា ឥតមានមហេសី ៗ ឯឈ្មោះសេនា មាន នាមហៅថា អយ្យបុត្របុរី ប្រសើរអនេក គ្មាន២លើដី ទើបអគ្គ អាសុរី ជំនុំពលផង ៗ ដើម្បីគិតគូរ រកមិនឲ្យយូរ គូព្រេងប្រាស់ បង្ង ទីងរកអ្នកណា ឲ្យសមគូគ្រង គ្មានតាមទំនង ស្គូស្រីជើរ· ជាស ៗ បានជាប្រជុំ ក្រុងយក្សជាធំ ទង់មានតម្រាស់ហៅពល

ឲ្យមក មីរនៅក្រែក្រាស់ ឲ្យដឹងក៏ច្បាស់ រកគូព្រេងព្រេង ៗ វិរុឡ្ហមេឃយក្សា ទ្រង់មានតុក្ការ ជាវិយពួកមិត្ត ឥឡូវមហេសី អញអត់មានពិត ប្រេះប្រូរឥតគិត កប្បកលនានា ៗ មើលសព្វទិសផងនគរបម្រុង ប្រែនក្រែមហិមា ក្រែងលោស្ដេចណា មានបុត្រពុំការយើងសូមភាជា ធ្វើជាមហេសី ៗ កាលណោះពលយក្ស ក៏បានស្ដាប់ជាក់ រំពឹងមើលទ្វី គ្រប់ទិសជម្ពូទ ដែលធ្លាប់ជាស្ដី ទើបមានកាស៊ីរ នៅខាងចុងរដ្ឋ ៗ លើកហត្ថបង្គំ វិរុឡ្ហមេឃជាធំ ជាសូមចមមកុដ ខ្ញុំដឹងរឿងពិត ដោយជាក់ប្រាកដ ក្រៃមាត្យទោមរត្ន ទ្រង់មានបុត្រី ៗ ល្អនោះពេញល្អ សាច់មិនខ្មៅស សម្បុរខៀវខ្ចី ទូលបង្គំដឹងពិត គឺទ្វីល្បី ជាកល្យាណី ប្រសើរឥតទាស់ ៗ ព្រះនាមកមល្ងគា គឺល្អស្ងារ្យ គាប់ពិតឥតខ្ចោះ ទូលបង្គំព្ទជាក់ ឥតមុសាសោះ បើមិនជឿប្រោះ សូមថ្វាយជីវី ៗ ក្រុងយក្សបានស្ដាប់ ត្រេក-អរបំណាច់ ទើបមានព៌ទី ជាបើជឿប្រោះ យើងគិតសក្ការ ធ្វើសារទៅទី ក្រៃមាត្យទោមយន្ត ៗ ឲ្យលើកបុត្រី ស្រស់កល្យាណី ស្រស់ស៊ើតជំទង់ បើមិនលើកទេ មុខជាសូន្យសុង យើងចូលទៅក្រុង រាយខ្ទេចស៊ីមា ៗ ធ្វើឲ្យប្រាកដ មុខទីងប្តឹងរដ្ឋ តាំង២អស្ចារ្យ គិតក្លាយក្រុងយក្ស វិរុឡ្ហមេឃចេស្ដា តែងជាអក្ខរា បានរូបជាម្ដង ៗ ចិតស្រោមយានស្អាត ទើបហៅអាមាត្យ ៣មកសារសង់ ជាអើងយកសារនេះទៅផ្គង ក្រៃមាត្យប្រាស់ប្រង់ កុំឲ្យយូរយា ៗ សេនាបាន

ស្លាប់ ហត្ថគីរទៅចាប់ សំពុត្រមីយ៉ា ទាំងពាក្យពួកយក្ស ហោះហើរ វេហាស៍ មិនត្រឹកោមា ចាប់ណកស់លឿនទៅ ៗ ដោយបុត្តិយក្ស ហោះដូចព្រួញថ្លា មិនយូរតាមឆ្ងាំ មួយដំពាស់ដៃ ដល់ដែនលំនៅ យក្សចុះសំរោប ប្រាសាទរោមចាយ ៗ ដល់ហើយបង្គំ ក្រមាត្យ ជាធំ មានបុត្តិសាយ ដល់ហើយលើកសារ បង្គំថ្វាត់ថ្វាយ ឲ្យក្សត្រ ពណ្ណកាយ គង់ពេលនោះនៃ ៗ ក្រមាត្យក្រុងយក្ស ហែកសារ មើលជាក់ ស្រាបហើយមិនភ័យ ព្រះអង្គទ្រង់ក្រោធ ទើបតែងសារវៃ ជាក់ជាសេចក្តី ពាក្យមិនខ្វាបឡើយ ៗ ហើយបិទកដសារ ផ្ញើរទីង អាសុក ពួកទូតជាត្រើយ ថាសូមយកទៅ ថ្វាយស្តេចយក្សព្រើយ ឲ្យដឹងជាត្រើយ គង់ពេលនេះឯង ៗ ពលខាងឯយក្សបុត្រ នៃបុរី រដ្ឋ បានក្លាមហោះស្ទើង ត្រាច់លើអាកាស ហោះលឿនគង់ត្រង់ បានដល់កំផែង ប្រាសាទពណ្ណកាយ ៗ ចូលទៅវន្ទា វិរុឡ្ហមេឃក- ជា ថ្វាយដល់ព្រះកាយ ព្រះអង្គបាប់សារ ហែកក្លាមទតខ្លាយ សេចក្តីអធិប្បាយ ដូចេះឯងថា ៗ ក្រុងក្រមាត្យយក្ស មានបុត្តិ ស័ក្តិ សូមប្រាប់ក្សត្រា អង្គវិរុឡ្ហមេឃ ចង់បានកញ្ញា ខ្ញុំក៏មិនថា មានអ្វីថ្វាយបាន ៗ ប៉ុន្តែនាងនេះ បេះអើយសែនបេះ រកគេផ្ទឹមគ្មាន ទើបខ្ញុំឲ្យផ្សែសារ អ្នកណាដែលមាន បុត្តិជាយាន ទើបឲ្យកូនស្រី ៗ ទើបមានស្តេចមនុស្ស មានបុត្តិបំពោះ លើកសរប្រូចខ្ញុំ ខ្ញុំក៏ថ្វាយទៅ នាងមានស្វាមី ហើយស្តេចត្រឹ ចង់សូមពាលពៅ ៗ សូមយាងទៅ

ថ្វាយ សុវណ្ណហង្សត្រោមត្រាយ ក្រោមបាទានៅ នោះលោកប្រទាន
ស្រីស្នំនៅៗ ថ្វាយភ្នាមភ្លៅៗ ឥតយូរការសោះ ៗ វិញ្ញូមេឃទត
ដាក់ព្រះរាជសារក្ខាត់ ពីព្រះហត្ថស្មោះ ញ៉ាំរព្រះកាយា ទើបថ្ងឹង
ឥតឡេះ អំពលទាំងអស់ ក្នុងរៀបប្រញាប់ ៗ យើងទៅកាយល្អុក
ក្រែមាត្យអាគុក ឡើងជើងចាស់ រាមើលឆាយព្រហ្ម អានេះខុសច្បាប់
ចាប់រាមកកាប់ ដោតទង់ជ័យដាត ៗ ទៅទូងស្គរជ័យ ឆាប់ៗវ៉ៃៗ
ភ្លាមៗខ្ទឹមឃាត ចាប់អាត់រប្អាន យកមកពិឃាត កុំឲ្យឃ្លាឃ្លាត ដូច
អញ្ចារបែង ៗ ពលក្តុទក្ការ ទាញមោងយាត្រា រាយស្គរគត
ក្រែង ក្តលាន់គ្រប់ទិស ពលយកត្រូតម្តង នៅដោយកំផែង ទីព្រៃ
បក្តូតា ៗ ហោះមកប្រញាប់ ច្រើនណាស់អឹងកាប់ គាល់ព្រះចេស្តា
ជើងព្រះឆោមយង់ មហាឆ្នុទក្កា បានពលយាត្រា មកច្រើនគគសល់ៗ
សុទ្ធតែបំភ្លមត ភ្ជាប់ចូលប្រយុធ ច្រើនក្រខ្វាយខ្វល់ មកមិរផេរផាស
ថ្វាយព្រះទសពល ព្រះអង្គទតយល់ គៅសិបសមុទ្រ ៗ ទើប
វិញ្ញូមេឃ ពាក់សុទ្ធអាវដែក ហើយទ្រង់ពាក់មកុដទ្រង់មានរាសី ដោយ
ភ្ជាប់ប្រយុទ្ធ ឥតមានតក់ស្លុត ពីសូនជ្រះ ៗ ព្រះភក្ត្រក្រហម ចាប់គ្រឿង
ឥតឋម ហាក់ដូចអគ្គី ចាប់ដម្រង់ជ័យ យក្រមកគ្រី នាំពលហោះម៉ើរ
លើនភាល័យ ៗ សន្ធឹកអស្ចារ្យ ពលយក្សអសុរា ដែលនៅក្នុងព្រៃ រត់
ជាន់គ្នាស្លាប់ អឹងកាប់ទីទៃ ដោយអង្គបមព្រៃ វិញ្ញូមេឃត្រោមត្រាយៗ
គង់លើហត្ថី គឺសត្វដំរី មានបុទ្ធិសាយ ហោះដល់ព្រលប់ ទើបស្តេច

ពណ្ណរាយ បានដល់ផ្សាយឆ្ងាយ នាបុរីរដ្ឋា ។ វិរុឡ្ហមេឃយក្ស ស្ដេចបានដល់ផាត់ ទើបមានឱង្ការ ថាអ៊ីយសេនីយ រៀបត្រៀមពួក នៅបុរីសេមា ចាំព្រឹកសឹមទៅ ។ លុករាយតែម្ដង វែងយល់ហើយ ហោង អាចារហោរទៅ ព្រហើនគស្វារ កុំទុកឲ្យនៅ យើងចូល សំដៅ ចាប់កាឲ្យបាន ។ ពលយក្សកំណាច ចាប់ដំបងភក្ស ហើយ អធិដ្ឋាន កើតជាប្រាសាទ ល្អស្អាតបំណាន ថាយក្សត្រើងថ្កាន ចូល ផ្ទុំទិត្យនៅ ។ លុះដល់ព្រឹកព្រាង លើកពលឥតល្អៀង ដើរចូល សំដៅ ឥតឲ្យដឹងប្រាណ កាយស្មានតាមផ្លូវ ឲ្យឃើញយក្សនៅ តែ គង់បុរី ។ ចាប់បានហើយចង ខ្ទះកាយបាក់ខ្នង ទាំងយក្សប្រុសស្រី មិនមានមេត្តា ករុណាប្រណី ស្លាប់ជាសពេញដី គណនាមិនអស់ ។ ឯយក្សស្រុកវិញ ពាល់ជើងប្រឹងដេញ កាប់ឥតស្រណោះ យក្ស ស្រុកមិនខ្លាច កាប់យក្សដែលបោះ ខ្ទះត្រូវពួតស់ ស្លាប់សូន្យជីវ ។ ខ្ទះបូលមិនរួច យក្សស្រុកគ្រប់ចួច ប្រឹងពីដើមទី ស្លាប់ច្រើនភាគសើ នៅពេញធានី ជាសជាលប្រថពី ឈាមដូចសមុទ្រ ។ ក្រៃមាត្យយក្ស យង់ ព្រះចៅមានទ្រង់ នាំពលតយុទ្ធ មិនស្ដាយជន្មា ព្រះទ័យបម- មកុដ យក្សស្រុកវឹរុទ្ធ កម្ចាំងសើគ្គា ។ កាយជាងពាវថ្ងៃ យក្ស ស្រុកទទួលដៃ ស្លាប់ច្រើនគណនា រាប់មិនអស់ឡើយ នៅលើពសុធា យក្សព្រៃនោះវា មានឫទ្ធិបំណាន ។ វិរុឡ្ហមេឃទោមទាយ លើក សរសេពសាយ បាញ់ក្លាមាទៅថ្កាន កើតជាបំណង ទៅចងគ្រប់

ប្រាណ ក្រៃមាត្រក្រត្រកក្កុន ដោយទន់ប្លុង ៗ ចំណង់ចង់ដាច់ ដោយមិន
ស៊ូវ៉ាច់ អន់ឫទ្ធិសៀវភើ ទំរើតរួច ពួកយកស្រគី ចូលទៅចាប់លើ នាំមក
ដាម្ពង់ ៗ ថ្វាយវិរុឡ្ហមេឃ ដាក់ក្រេតធាមឯក ទ្រង់ទតទៅគង់ ដេរថាយីអើ
អាចោរដកចង់ មុខដូចដាក្តង់ ព្រហើនអស្ចារ្យ ៗ ហ៊ានដៀលគុះអញ
ឲ្យទៅធ្វើបាញ់ ខ្មោចអាមនុស្ស មើលងាយតូចព្រហ្ម អាចោរមុខខ្វា
ចាប់ទៅប្រហា កុំទុកឡើយនៃ ៗ ក្រៃមាត្របានស្តាប់ ក្តៅណាស់
សារស័ត្ត ទើបធ្វើយទៅវៃ អញស្មាប់មិនស្តាយ មិនមែនចោរព្រៃ កុំ
តែបុត្រថ្ងៃ សុវណ្ណហង្សមានឫទ្ធិ ៗ បើសិនគេនៅ អាឯងមានផ្លូវ បង់ខាត
ជីវិត ខានជួបខានឃើញ ប្រទេសស្ថានស្ថិត ខ្មោចចោលឥតជិត
កន្សែព្រឹងហើយ ៗ តាំងពលសេនា គ្មានបានយាត្រា ទៅនៃអាអ័យ
អញប្រាប់ឲ្យដាក់ ពេលនេះឲ្យហើយ កុំបែបព្រងើយ ធ្វើគ្រាន់បើផង ៗ
អាឯមានវិជ្ជា ធ្វើមន្តនានា មកចាប់អញចង់ មិនអើពេអា ដាក់នេះជា
មួង ជាតិក្រោយសុំសង់ កាប់អាឯងទឹង ៗ អាយកទៅណា អញអត់មាន
ថា ចិត្តកំម៉ិនទឹង សុះចិត្តតែស្លាប់ អញប្រាប់ឲ្យដឹង ឆាប់នាំទៅវៃ
ទៅតាមសីរ៍ ៗ វិរុឡ្ហមេឃបានស្តាប់ សែនក្តៅចំណាប់ ទ្រង់ទុក្ខារ
ខ្ញី ថាវិឃ្ឃយកទៅ ដាក់ទ្រង់សិននៃ ចាំឲ្យបុត្រថ្ងៃ រាល់ស្រស់បេស្តា ៗ
ឲ្យដឹងតូចព្រហ្ម ដែរដើមប៉ុនក្ដ ឥតមានវេអា មិនដែលញញើត អា-
ចោរមនុស្ស វាមកប៉ុនណា ចាប់ស៊ីប៉ុណ្ណោះ ៗ មិនឲ្យស្តាប់ទាន់
តែនៅគ្រាន់ ៗ លេបរាំតាំងរស ឲ្យដឹងតូចព្រហ្ម ដែលហ៊ានមកទាស

មិនមែនដូចផ្នួស គ្មានរបេះសីល្បសាស្ត្រ ៗ ថាហើយសេនី បណ្តើរ
ចេញទ្វី ទៅយ៉ាំងរហ័ស ដាក់ទ្រុងដែកជាប់ មុខដូចឆាប់ប្លាស់ ក្រៃ-
មាត្យសែនខ្មាស់ មួរគដ៏ឥន្ទ្រិយ ៗ ជាប់នៅយប់នោះ ព្រួយចិត្តចំ-
ពោះ យក្សព្រៃកាតទី ចូលលុកបុរី ចាប់យកស្រីញី ពាសពេញ
ធានី ឥតមានប្រណី ៗ អាសូរយក្សស្រុក ព្រួយប្រាណជាទុក្ខ
ទាំងប្រពន្ធប្តី យក្សរាំងដេញចាប់ ឥតគិតថាអ្វី យកមកបេតី សប្បាយ
អឹងកង ៗ ជូនពីក្រៃមាត្យ លំបាកដល់ខ្មាត ដោយជាប់ចំណង
ទើបលើកហត្ថា សច្ចាទៀងផ្ទង់ ថាសូមប្រាស់ច្បង់ ទេវិន្ទចមក្រែ ៗ
បើខ្ញុំនេះ បុណ្យមកកេះ ហើយមានទិស្ស័យ ទឹងកូនប្រសារ
សុវណ្ណហង្សត្រៃថ្ងៃ សូមជួយកែខ ឲ្យរស់ជន្មា ៗ ឱព្រះទេវិន្ទ
ដែលជាទេវិន្ទ មានស័ក្តិមហិមា សូមព្រះគុណថ្ងៃ នាំទុក្ខនេះជា ទៅ
ប្រាប់បុត្រា ឲ្យបានដឹងផង ៗ ដ្បិតខ្ញុំមានទុក្ខ ហាក់ដូចជាប់គុក
នៅក្នុងចំណង ហេតុនេះសូមជួយ ឲ្យរួចជាមួង បានដូចបំណង ណា
ព្រះមានបុណ្យ ៗ ថ្លែងពីទេវតា មានឫទ្ធិបេស្តា ជាអនេកលន់
បានស្តាប់ពាក្យយក្ស ជាក់មិនបង្អង់ ដោយយក្សមានបុណ្យ ទឹងព្រះ
ក្សត្រក្សត្ត ៗ មើលដឹងហេតុកេច ទេវតាសង្កេត ដឹងជាក់ឥត
ស្ថាន ថាស្តេចមកជួយ មុខជារួចប្រាណ ទើបទ្រង់ហោះឋាន ទៅទាំង
រាត្រី ៗ ទៅដល់ប្រាសាទ ដែលព្រះឆោមស្អាត ផ្ទុំនិទ្រមហេសី
កំពង់លក់លន់ ឥតមានដឹងអ្វី ទើបលោកពោលខ្ញី ត្រាស់ហៅទៅ

ថា ៗ អើសុវណ្ណហង្ស អ្នកមានបុទ្ធិរង្ស ទៅជួយបិតា ឲ្យស្តេច
កើតភ័យ ដាប់ទ្រង់អសុភ ចង់បានកម្លូកា នោះឯងប្រាកដ ៗ
សូមស្ដេចយាងទៅ កុំផ្ទិនិត្យនៅ ណាព្រះបមមកុដ កុំឲ្យយូរយារ ឲ្យ
ឃើញផាប់ផុត ទេវតាស្តីផុត កៀសខ្លួនបាត់ទៅ ៗ ថ្លែងពីមហាក្សត្រ
ដឹងព្រះកាយថ្វាត់ ត្រស្បូវគ្រកៅ បានស្តាប់សូរសៀង ទេវតាហាហៅ
ព្រះអង្គមិនសៅ បានដឹងជាក់ការណ៍ ៗ តើនទាំងរាត្រី កេះប្រាប់
មហេសី ទាំង៣ប្រាប់ថា អើកែវព្រលឹង បូរតើនឡើងណា ឲ្យត
មានទេវតា មកប្រាប់សេចក្តី ៗ ថាមានយក្សឆើត មកចង់ក្រអឹត
យារយើបុរី ឯក្រុងមហាក្សត្រ គ្រែមាត្យវរបី ហេតុនេះប្អូនស្រី បង
សូមលាស្ងួន ៗ នៅណានាងណា ចាំថែរក្សា រូបកាយរៀងខ្លួន បង
សូមលាស្រី ទៅហើយណានួន បិតាទុក្ខធ្ងន់ នៅជាប់កង្ទ្រង់ ៗ
កមល្ងកាឆើតឆាយ បានស្តាប់អធិប្បាយ ព្រះសុវណ្ណហង្ស នាងវរវន្ទ
ដល់ព្រះធោមយង់ សូមតាមព្រះអង្គ ទៅផងប្រាកដ ៗ សូមលា
អកឹម សុរិយង្គនួននឹម នឹងវិលទៅរដ្ឋ តាមព្រះស្វាមី ដោយជាក់ណាត់
ព្រះនាងលើកហត្ថ បង្គំទាំងពីរ ៗ ស្ដេចក៏ផ្ដាំនួន សុរិយង្គមាស
ស្ងួន អកឹមទេវី ថាបងលាទៅ ហើយវិលមកទី មិនបោលសោកី
ឲ្យយូរដូចមុន ៗ បក្រាំងរូបកាលណា កុំប្អូនទុក្ខា ណាតូចមាសគន់
មិននៅយូរទេ វិលក្បាមឲ្យទាន់ ដួបកែវសោកណា មិនមុសាឡើយ ៗ
នារីបានស្ដាប់ ស្វាមីសារស័ព្ទ ទើបនាងនាថឆ្លើយ ថាព្រះអង្គយាង

គោលប្អូនទៅហើយ កុំឲ្យបារម្ភឡើយ ចាប់លើកស្រី ៗ ព្រះអង្គបាន ស្ដាប់ កញ្ញាសារសព្ទ ត្រេកអរឥតបី ចូលស្រាយកណ្ដក់ ដែលមាន បារមី ហើយនាំប្រឹមប្រិយ គង់លើខ្នងផាក់ ៗ ទាញខ្សែអស្សតរ ទ្រង់បោះបញ្ចរ ចាំងយប់ស្ងាត់ស្ងាក់ ងងឹតអនេក ព្រះទោមទ្រង់ លក្ខណ៍ ដោយព្រះទ័យស្មគ្រ អាស្សបិតា ៗ សេះបោះលឿនក្រៃ ដូចព្រួញវិស័យ លឿនក្រៃអស្ចារ្យ អាស្សព្រះនាង ទូនកែវកមលុគា សើរសូន្យដីភ្នំ នៃសួនកល្យាណ ៗ បោះទាល់ជិតភ្នំ ជិតដល់ ហើយគឺ មើលព្រឹលហាក់ស្ងាន យល់ដែនប្រាកដ សេះបោះដល់ ឋាន មើលទៅក្រុងស្ថាន គ្មានឃើញមនុស្សម្នា ៗ ស្ងាត់ជ្រៀប ទាំងអស់ ឃើញដើរលេក្រះ ៗ កាន់គ្រឿងនានា សុតតែពួកព្រៃ ទើបព្រះពជា បែរទៅត្រកូមា ទៅចុងបុរី ៗ ឃើញទ្រង់ប្រសើរ ពួកយាមនៅដើរ ចាំព្រះបរមី ព្រះអង្គយល់ផាក់ ទើបសេពបាលី ផា ដំនោរទ្ធី ត្រជាក់គាយេ ៗ សណ្ដំពលមារ ដែលឈរគេគៀរ ត្រូវ គ្មានសល់ទេ ទាំងវិញ្ញូមេឃ ងុយដេកឡើងទេ ព្រះអង្គប្រឹងតែ សុត្រ ថែមទៀតទៅ ៗ ដេកលក់ទាំងអស់ ខ្លះផ្លូលស្រស់ ៗ ដេកដើរ តាមផ្លូវ ខ្លះកំពង់យាម ដល់ភ្នាមឥតនៅ ទើបព្រះបមចៅ បោងបុះ តែម្ដង ៗ ដល់ទ្រង់គាលណា ទើបប្រាប់កញ្ញា កមលុគាទូនល្អង ឲ្យថ្វាយបង្គំ ក្រៃមាត្សបារាស់ប្យង៍ សោកហើយសារសង់ សួរហេតុ ក្សត្រថ្ងៃ ៗ បពិត្រព្រះគុណ ព្រះអង្គមានបុណ្យ ខ្ញុំព្រះអង្គសង្ស័យ

បុះហេតុដូចម្តេច បានជាទុក្ខក្រៃ កូនជាប់អាល័យ ពោលទ្រង់យូរ
ណាស់ ៗ ទើបតែបានដឹង ដំណើរផ្សេង ៗ ដោយទេវតាប្រាស់
ថាព្រះបិតា មានទុក្ខក្រៃក្រាស់ បានជារហ័ស មកជួយព្រះគុណ ៗ
ទើបអង្គក្រៃមាត្យ ព្រះទ័យពេញស្អាត ប្រាប់ទៅកូនគន់ ពីរឿង
វិរុល្ហមេឃ ដើមឃ្លាពីមុន មិនឲ្យសឹយសុឹន គ្មានខុសដោយពិត ៗ
ស្តេចស្តាប់បិតា ចាប់ព្រះច័ន្ទប៉ា កាប់ទ្រង់ឥតគិត ដោយព្រះបារមី
នៃព្រះច័ន្ទបុត្រ កាប់ខ្វាយឥតជិត ទៅ៥យោជន៍ឆ្ងាយ ៗ ហើយទាញ
បិតា បានមកកាលណា នៃក្សត្រចោមចាយ ស្តេចក្តៅខ្លាំងណាស់
ក្រៃមាត្យអង្គកាយ គិតចូលទៅរាយ វិរុល្ហមេឃអាសុរី ៗ ប្រុងទៅ
សម្លាប់ សុវណ្ណមាងព្រលោកចាប់ ឃាត់ព្រះវរបី កុំឲ្យសម្លាប់ រ៉
អាប់សិរី ចាំព្រឹកឡើងថ្ងៃ សិមលបេស្តា ៗ ឲ្យរាំបានដឹង នៅបុត្រ
ផ្សេង ៗ នៃអង្គមនុស្ស បាញ់រាំឲ្យស្លាប់ នៅទឹងសរថ្នា ឲ្យរាំដឹងថា
មនុស្សមានសីលស្រ័យ ៗ បើយើងសម្លាប់ មនុស្សដេកដូចអាប់
ស្មុយឈ្មោះពេកក្រៃ ចាំសម្លាប់រស់ ទើបមានថ្វីដៃ សូមព្រះក្សត្រ
ថ្ងៃ ប្រាបកន្ទ័យា ៗ ស្តីស្រេចជាម្តង នាំក្សត្រប្រាស់ច្បង ទីង
ស្រស់សោភា យាងចូលបុរី នៃក្រុងរាជា ទ្រង់គន់សុខា ក្នុងរាជដំ-
ណាក់ ៗ តាំង៣ព្រះកាយ ចារចែងអធិប្បាយ ល្បះដល់ក្តីជាក់ ព្រះ
អាទិត្យរៀងរះ ក្តីបែងបុត្តិស័ក្តិ ទើបបានពលយក្ស រាក្សាក់ដឹងខ្លួន ៗ
វិរុល្ហមេឃតើនភ្ញាម ដោយធ្លាប់សង្គ្រាម បេះចាំម៉ាមួន ឃើញក្តីត្របះ

ស្ដេចព្រាយទុកប្អូន មិនគួរស៊ីនខ្លួន ដេកដួលប្លុះឡើយ ៗ ឃើញពល
ដេកត្រៀប ដេកគរគម្រៀប មហាក្សត្រត្រាណត្រើយ ទ្រង់ស្រែកដាស់
ហៅ អឺអាដែងរ៉ុយ ក្មួយដេកព្រងើយ មិនដឹងកលអ្វី ៗ អាពោរ
គេកាប់ ដេកដូចជាស្លាប់ ឆាប់ក្រោកឡើងវិញ ប្រញាប់ឆាប់ៗ ទឹង
រៀបសេនី ក្រែងមនុស្សបារ្ដៃ វាតាមបិតា ៗ ដាស់យក្សក្រោក
អស់ អ្នកយាមផងស្មោះ កើតក្ដីទុក្ខា ឃើញទ្រង់បាក់បែក គ្មានសល់
ត្រង់ណា ឡើងទូលក្សត្រា ដោយការណ៍ភ័យណាស់ ៗ ដល់ហើយ
បង្គំ នៃព្រះបរម វិរុឡ្ហមេឃជាម្ចាស់ ថាទ្រង់ក្រៃមាត្យ បេញបាត់
ស្រឡះ សូមក្សត្រជាម្ចាស់ ជ្រាបល្អដ៏ធ្លូល ៗ វិរុឡ្ហមេឃបានស្ដាប់
ពាក្យពលសារសព្វ ក្ដៅដូចអគ្គី ចាប់ដំបងពេជ្រ លើកឡើងគ្រវី
ញាប់ញ័រតម្រិយ ថ្វាថ្ងូងទៅថា ៗ អ៊ឺ! នៃគ្នាយើង ប៉ុរអ្នកប្រុងគ្រឿង
ក្នុងពេលនេះណា មុខមានអាដែង កំពូលមនុស្សា ចិត្តវាហានក្លា
ចូលយកមនុស្សទោសៗ វាមានឫទ្ធិសម អាងបេះសណ្ដំ អានេះពេញខុស
ព្រហ៊ើនអង់អាច បេះបូរប្រុងបុះ វាគ្មានប្រមុះ ពូកែខ្លាំងក្រៃ ៗ អញ
ចាំចាប់ធា ខ្មោចអាមនុស្សា ធំជាងមេដៃ ចាប់លេបចាំងមូល ខ្មោច
អាចក្រៃ មិនកាប់ដើងដៃ លេបវាទាំងរស់ ៗ ពលទ័ពតេតគងាយ
ប្រុងប្រៀបរៀបកាយ ប្រាកដពេលនោះ វាយលុកបុរី ឥតមានពិគ្រោះ
ខ្លាចព្រះទ្រង់យស បង្គំជាមួង ៗ ប្រុងគ្រឿងកាវុធ សុទ្ធយក្ស
ចិត្តមុត វាយបរបូលផ្គង ទើបអង្គទេវិទ្ធ សុវណ្ណហង្សប្រាសប្រាង ពុ

សូរអឺងកង ស្តេចឃានមកឃាត់ ៗ តែព្រះអង្គឯង ឃានដល់ថ្វា
ថ្ងៃង ពេចាបេះស្នាត់ ថាវ៉ុយចោរព្រៃ កុំបួលប្តូររដ្ឋ កស្ត្រុយើងនេះ
រត់ ឥតសល់ត្រង់ណា ៗ ដោយពួកអ្នកឯង បួលមកកំហែង ចង់
យកសេមា ថយចេញឲ្យឆាប់ ក្រែងកើតទុក្ខា ចេញពីរដ្ឋា នៃខ្ញុំ
អញទៅ ៗ ចំពោយក្សឆ្លើយថា ឯងមកពីណា ចូរឆៀសកុំនៅ អញលេប
ទាំងរស់ គ្មានគិតរាក់ជ្រៅ មកចចឹងផ្លូវ នាំឲ្យសៅហ្មង ៗព្រះអង្គឆ្លើយថា
ខ្មោចអាយក្សា ដំខ្លួនកន្ទួង ដូចជាទន្សាយ ចាញ់ប្រាជ្ញាខ្លួន អាឯងនេះ
ហោង ដូចទន្សាយដែរ ៗ អាឯងខ្ញុំគ អញមិនស្តីទេ ដូចជាសត្វក្អែក បើ
ទឹងម្ចាស់អា ទើបស្តីពូកែ ពេញជាព្រៃសៃ ក្សត្រៃដូចគ្នា ៗ ពលយក្ស
បានស្តាប់ ឮវាក្យសារសព្ទ ពហោគ្គិគា ថាវ៉ុយចូរចាប់ អាមនុស្សពាលា
ទឹងយកទៅគ្នា ស៊ីធីកសប្បាយ ៗ ហោះកោមង៉ឹត ប្រុងចាប់ដោយបុទ្ធិ
ឥតមានទឹកស្តាយ កោមង៉ឹតផាស លើអាចាសន្ទាយ ទើបក្សត្រពណា-
រាយ ចាប់ផ្គួសរជ័យ ៗ លើកយិតបាញ់យក្ស ឥតមេត្តាផាក់ លើ
ខ្នងយនោម័យ ពួស្ករចាំង ១ ឆាប់ផាសពេញព្រៃ កប់ទៅផាង ២០
សមុទ្រដលធី ៗ ពួដូចរន្ទះ រំលោមេឃ ស្តាប់បក្រស់ ញាប់ញ័រ
ឥន្ទ្រិយ ក្តៅណាស់ហោះរឹង មកឈរសំគីរ ចង្អុលដៃ២ ទៅព្រះ
ដោមឃង់ ៗ នៃវ៉ុយមនុស្សា ឯងមកពីណា បិត្តកាចទ្រនង់ ព្រះ-
ហើនអស្ចារ្យ គ្មានខ្លាចពូជពង្ស យើងនេះជាអង្គ ឥស្សរឆែតឆាយ ៗ
បើអ្នកចង់សុខ ចង់មានមាត់មុខ ត្រូវអ្នកទុនកាយ បង្គំនៃអញ ទើប

បានរួចឆាយ ឈោមឲ្យស្រាយ ទើបបានសួរស្ដី ៗ បើមិនបង្គំ
ខ្លួនអញជាធំ គាត់យកសិរសី សាច់ឈាមឆ្អើញ៉ាំ ស៊ីគ្មានប្រណី ឲ្យ
តែដរី ចង្ក្រាំងគង់ឈ្មោះដែរ ៗ ស្ដេចស្ដាប់វិរុឡ្ហមេឃ ក្ដៅណាស់ពន់
ពេក ទើបឆ្លើយថានៃ អាពោរខ្មោចយក្ស អ្នកឯងពូកែ មុខដូចជាឆ្កែ
ហ៊ានមកពោលថា ៗ ឲ្យអញសំពះ ផ្ទើបុកដូចព្រះ រ៉ុយនៃអាស្វា
បើស្លាយជីវិត ចូរលើកហត្ថា ក្រាបទិនសិរសា បង្គំអញនៃ ៗ នោះ
អញលើកទោស ពោះបីត្រូវខុស ដ្បិតស្មុគយក្សព្រៃ អញអាណិត
ណាស់ គ្រប់រូបទីទៃ បានជាអញលៃ ឲ្យសុំទោសពិត ៗ វិរុឡ្ហមេឃ
បានស្ដាប់ ក្ដៅញ័រចំប្រប់ ទាញដំបងឫទ្ធិ ថារ៉ុយអាពោរ កំណាច
ទ្រស្តមិត្រ ពេលនេះពិនិត្យ ត្រូវប្រឹងកាយ ៗ អញមិនទុកឡើយ
ស្ដីស្អុះកន្ដើយ លោតវាយកម្ពី ប្រឹងវាយសម្លាប់ ឲ្យដួលដួល ពួកពល
ចូលមីរ ហោមពោមត្រៀបត្រា ៗ ព្រះពោមទេវិន្ទ ព្រះអង្គស្ដេចប៊ុន
ធ្លាប់ច្បាំងច្រើនគ្រា ហូតខ័នគ្រី តទល់យក្សា ទល់ទប់ចេស្ដា បម្រុង
យកជ័យ ៗ ពលមារច្រើនណាស់ តែស្ដេចរហ័ស ក្បាច់ក្បួនលេងលៃ
ហូតធ្នូសរថ្វា បាញ់ក្វាមឥតភ័យ ស្លាប់ពលវិស័យ ដូចសត្វចាំងឡាយ ៗ
បាញ់៤-៥ ដង ពលជាក់ឥតហ្នឹង ស្លាប់ច្រើនឲ្យពាយ ដោយហេតុ
តេជះ នៃព្រះនរាយន៍ យក្សព្រួយគួរកាយ ស្លាប់ច្រើនក្រៃក្រាស់ ៗ
វិរុឡ្ហមេឃអស្ពុក ឃើញពលអាត្មា ស្លាប់គរច្រើនណាស់ ក្ដៅដូចអគ្គី
ស្អុះចូលរហ័ស វាយទិនក្សត្រម្ចាស់ គ្មានញញើតប្រណា ៗ យក្ស

កាប់ស្តេចវង់ ស្តេចធាក់យក្សចង់ មិនត្រូវក្សត្រក្សាន្ត យក្សវាយ ស្តេចវ៉ាត់ ទាត់ធាក់ទៅថ្កាន សុទ្ធតែបំណាន មានបុទ្ធិ៍បារមី ៗ ទើប ព្រះក្សត្រា ទាញធ្នូសរថ្វា បាញ់ផ្កាប់សិរសី ពស្មូរតែធាំង ស្លាប់ ក្លាយកើត៣ ចូរប៉ាំងចក្រ ប្រែចមីនិត្យនៅ ៗ ព្រះអង្គព្រួយព្រាណ ទឹងយក្សក្សត្រក្សាន្ត កើតព្រៃនពេកក្រូវ មួហង្កកង្កបិត្ត ព្រះទ័យពេញ ក្តៅ វៃក្រង់បាញ់យក្សទៅ នាំអាប់កេរ្តិ៍ឈ្មោះ ៗ យក្សក៏ក្តៅក្តាត់ លើកដំបងថ្វាត់ ចោលចំព្រទង់យស កើតជានាគា រោមក្សត្របំពោះ ព្រុងមិនឲ្យរស់ សម្លាប់ក្សត្រថ្ងៃ ៗ ប៉ុន្តែព្រះអង្គ ទាញធ្នូបញ្ចង្គ កើត ជាគ្រុឌវៃ ចាប់នាគទាំងឡាយ បិកសុីតតក័យ យក្សព្រួយព្រះទ័យ ទាញយកដម្បង ៗ ចោលទៅម្តងទៀត បំព្រះនរនាថ កើតជាភ្លើង ឆ្គង ព្រះអង្គបានឃើញ ទាញសរបាញ់ផ្លូង កើតខ្យល់ជាម្តង ផាត់ ផាយភ្លើងអស់ ៗ យក្សចោលគ្រប់សព្វ ដោយក្តីសំអប់ តាមពិត ផាក់ស្មោះ តែធ្វើមិនបាន ចាញ់ព្រះចោមយស ពលក៏ស្លាប់អស់ គ្មានសល់១-២ ៗ យក្សក៏ភ័យព្រាណ ហោះរត់ចរថ្កាន ខ្លាចព្រះ ភូមី ហោះពួនពពក លាក់កាយឥន្ទ្រិយ ស្តាយផ្ទនជីវ៍ ក្នុងពេលនោះ ឯង ៗ ព្រះអង្គស្តេចដឹង ថាអាយក្សហ្មឹង រត់ខ្លាចវៃក្រង់ ចាញ់ សីលព្រះអង្គ នៅតែម្នាក់ឯង អង្គព្រះតម្តង ស្តេចហោះតាមទៅ ៗ ស្តេចទតយល់ជាក់ ឃើញកំពង់យក្ស រពួនទិត្យនៅ ត្រង់ក្នុងពពក ក៏ព្រះចមទៅ ទាញសរមកក្រូវ ហើយអធិដ្ឋាន ៗ ថាសូមទេវិន្ទ ឥន្ទ្រា

នរិទ្ធ នៅក្រលាស់ស្ថាន បើខ្ញុំថ្លែងទៅ កុំឲ្យរស់បាន ឲ្យយក្សស្លាប់ ប្រាណ ដូចពាក្យសច្ចា ។ គិតក្លាមបាញ់ជូន ត្រូវយក្សដាំដូង សូន្យផុនសន្ធារ ធ្លាក់មកដល់ដី ក្រៃអស្ចារ្យ យក្សស្រែកហោថា វិរុឡ្ហមេឃស្លាប់ហើយ ។ រន្ធឺស្នុះសាយ ព្រះអង្គធោមឆាយ ហោះចុះ ករន្ធើយ ចូលក្នុងកំពង់ជ័យ បាត់ទុក្ខបានស្បើយ ឯបអង្គបង្កើយ បង្គំ វរបី ។ បពិត្រព្រះគុណ កូនសម្លាប់ជន អាយក្សដេកដី ស្លាប់ សូន្យមិននៅ ដោយឫទ្ធីល្បី ខ្ញុំព្រួយឥតគ្នី ខ្លាចយក្សមានទ្រង់ ។ ស្លាប់មួយរស់២ នៅតែចូលមីរ កូនទទន់ជង្គង់ កុំអីស្លាប់ស្រេច តែបុណ្យ ទ្រទ្រង់ យក្សក័យហោះស្ទុង ពួនទីអាកាស ។ ចូលក្នុងពពក ខ្លួនខ្ញុំតាមរក បានឃើញយល់ច្បាស់ ទាញយកធ្នូជ័យ បាញ់ក្លាមក្តៅ ណាស់ ត្រូវបំមិនផ្លាស ស្លាប់ក្លាមជាមួង ។ ព្រះអង្គបានស្តាប់ ពាក្យ បុត្រសាសព្វ ចបថើបច្បាស់ច្បង ជាកូនមានគុណ វិសេសក្នុង គុណធំណាស់ហោង ស្មើបង្កើតប្រាណ ។ ឲកូនធោមឆាយ បិតា បានកាយ ជួយឲ្យបានគង្គ បានក្សេមខេមា កុំអីខាន អ្នកជួយឲ្យ បាន រស់ជួនបិតា ។ ទើបព្រះសុវណ្ណហង្ស ស្តាប់ព្រះបមពង្ស ស្តេចលើកហត្ថ បង្គំបមក្រៃ សូមលាយាត្រា វិលទៅសេមា អយុធ្យ បុរី ។ បង្គំទូលថា កូនលាបិតា ណាព្រះនរបតី ដ្បិតទាំងធោម- ឆាយ ពីរកាយមហេសី ថាឲ្យវិលវិញ នៅយូរមិនបាន ។ កូនទៅ មិនយូរ វិលមកវេគគួរ កមល្គាកល្យាណ សូមគង់ឲ្យសុខ កុំឲ្យរំខាន

សត្រូវមិនហ៊ាន យាយីទៀតឡើយ ៗ ក្រៃមាត្យស្ដេចយក្ស បាន ស្ដាប់ពាក់ទវគ្គ ព្រួយប្រាណឥតស្បើយ ទើបសួរទៅខ្ញី អីកូនត្រាណ-ត្រើយ បើបាទៅហើយ ចុះឆោមទើ ៗ ផ្ញើនឹងបិតា ប្ដូមួយបុត្រា ឆ្កួយកទៅទី ឲ្យជុំមហេសី នៃសួននារី បូរកូនសម្ដីរ ប្រាប់ពេល នេះនៃ ៗ ព្រះអគ្គបានស្ដាប់ ទើបទ្រង់សារស័ព្ទ ថ្វាយព្រះបមត្រៃ ថាសូមផ្ញើនឹង មិនយកទេនៃ ហើយចាំវិលវៃ យកប្អូនឆោមឆាយ ៗ ហៃកមល្ងកា បងលាហើយណា ស្រស់ស្ងួនតណ្ណាភយ បងទៅមិន យូរ ឆាប់វិលមកឆាយ ផ្ដេកផ្ដួលមកាយ លុះសូប្រស្នារ ៗ នៅ ចុះមាសស្ងួន បូររក្សាខ្លួន ឲ្យកាន់តំរិយា · បងលាសិនហើយ ហៃនៃ កញ្ញា នៅនឹងបិតា រក្សាខ្លួនទៅ ៗ នាងបានស្ដាប់ដាក់ ទឹក នេត្រស្រាក់ ទូលព្រះបមទៅ ថាបើស្ដេចយាង ឆាប់មករកពៅ កុំឲ្យ ប្អូននៅ តោះម៉ាយយូរលង់ ៗ ប្អូនទំពឹងបង . បីដូចប្រាសប្រង់ នៃ ព្រះមានទ្រង់ . ស្ដេចជួយស្រង់ប្អូន ពីកង់អន្ទង់ បិតាចមពង្ស បាន រួចជីវិត ៗ យាងទៅឆាប់មក ព្រះទ័យលៃលក រិះធ្យានឆាប់គិត កុំ យាងទៅយូរ ប្អូនស្ដាយទ្រង់បុទ្ធិ ណាម្ចាស់ជីវិត គួរគាប់ពីព្រេង ៗ ស្ដេចបានស្ដាប់ដាក់ ព្រះទ័យអួលអាក់ អាសូរបែកឈ្លង អាណិត ប្អូនគន់ សង្រែងសង្រេង ទើបព្រះគម្ដែង ហៅពជមនោម័យ ៗ នៃ បងនឹមកឆាយ ទៅនគរនាយ ឯយក្សត្រក្រងជ័យ សូមមកឲ្យឆាប់ តាម ច្បាប់ខ្ញុំវិល អសត្វអាជានេយ្យ ហ្មាលចូលជាម្ដង ៗ ស្ដេចទ្រង់ចាប់

វៀង ឯព្រះនេត្រវៃ ទៅរកទ្ធនល្អង នាងសោកសង្រោក់ ដាវផ្លូវ ចូាស់ចង្រង ព្រមទាំងពលផង ដាវផ្លូវចមទៅ ៗ ដល់បុរីសេមា ទើប ព្រះក្សត្រា ជាយសេះហោះស្ទៅ លើនគាល័យ ឥតមានហ្វុងសៅ កមល្ងកាស្រីពៅ ឡប់ចូលសេមា ៗ សឹងសុខសប្បាយ ប្រទេស ទាំងឡាយ រូបឬាបអា រទ្ធិកិត្តិយស ខ្ពស់លើទូបា មិនដែលជាតិ ណា ប្រុងមកតព្វាបាទ ៗ មានតែគោរព ឥតមានឈរឈប់ រួប ព្រះធោមស្អាត នាំសួយអឹងកង ថ្វាយដល់ក្រៃមាត្យ ប្រើនណាស់ ដល់ខ្នាត សប្បាយពេកក្រៃ ៗ យកត្រៃប់ទិសា ក្មួនាមហៅថា សុវណ្ណហង្សក្សត្រថ្ងៃ ព្រឹកព្រលបចរ់ត់ ទៅនៅក្នុងព្រៃ ដោយអំ- ណាចភ័យ ស្តេចមានបុណ្យ ៗ បានសុខសិរី មង្គលសួស្តី សប្បាយ សោកី សោភ័ណកបានសុខ គ្រប់ស្រុកគិរី ល្បីព្រះភូមិ រទ្ធិសុខ សាយ ៗ ទឹងសូមថ្វាវៃថ្ងង ពីអង្គតម្កង ស្តេចទំនូលរ៉ាយ ហោះដល់ សេមា វង្កាធោមធាយ ទ្រង់បន្ទាបកាយ បរចុះទៅវៃ ៗ ចូលក្នុងសី- មា បង្គំបិតា សុធន់ក្សត្រថ្ងៃ ទឹងសុចិត្រា មាតាបវណា បង្គំបមក្រៃ នូវទាំងទេ្យតិត ៗ បង្គំទូលថា កូនបរយាត្រា ណាព្រះបតិត្រ ទៅធ្វើ សង្គ្រាម ទឹងយកទ្រព្យខ្ចុរិត កូនពៅឥតគិត សម្លាប់ក្សិណក្ស័យ ៗ ឈ្មោះ វិរុល្ហមេឃ អានោះធំពេក បុនក្ខ័ស័យ ឆាប់១រស់២ ឆាប់១០កើត២០ ទំព្រះអង្គលកលៃ រាយយកក្យក្ស័យជន្ត ៗ បានលាបិតា ក្រៃមាត្យ យក្សា ចក្កុតសោភ័ណ ទឹងរែវកមល្ងកា ហោះដោយស្រួនគ្នន់ មក

បួលដំបន់ ទើបស្ដេចឆ្លើយថា ៗ អើនែបុត្រស្ងួន ឪពុកទុក្ខធ្ងន់ ខ្លាច
តែបុត្រា ទៅតាញសីល្បយក្ស កើតសូន្យសង្ខារ មិនដែលនរណា
ទៅទាំងកត្រិ ៗ ព្រះអង្គបានស្ដាប់ ក៏ទូលសារសព្វ ថាបូវព្រួយអ្វី
ទូលបង្គំផ្ដាប់ប្រាង ច្រើនហើយនរបតី យក្សស្លាប់ឥតបី ត្រាកប់បាន
ទៀយ ៗ ទើបថ្វាយបង្គំ ដល់ក្សត្រឧត្ដម ពេលនោះជាត្រើយ ទៅ
រកកញ្ញា ទាំងទ្វេកន្ដើយ មិនឈប់យូរឡើយ រឭកប្អូនស្ងួន ៗ ទៅ
ជួបតាសី នាងបានយល់ប្ដី ស្រីបាត់ទុក្ខធ្ងន សួរទៅបងឯសព្វ ត្រេក-
អរមាំមួន ដោយបានជួបជួន រង់កាយឆោមយង់ ៗ សឹងសុខសប្បាយ
ប្រទេសទាំងឡាយ នៃក្សត្របមពង្ស សឹងខ្លាចបុទ្ធី បារមីបុទ្ធិវង្ស
ក្រេមក្សាន្តយូរលង់ គ្រប់ទាំងភាគ ៗ

ចប់